អំពី

របស់ ចន្ទ្រាបុត្រ

# ស្នេហា

*de l'amour*



៨៦.
២៣

www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh    www.elibraryofcambodia.org**

www.budinst.gov.kh    www.elibraryofcambodia.org

ឡើយ ។ តែលុះវាចំរើនអាយុធំឡើង វាក៏ចាប់ផ្តើមខំចេះស្គាល់ " ស្នេហា" នេះដែរ ។

ក្នុងការសង្កេតរបៀបនេះ យើងអាចយកទ្រឹស្តីចិត្តវិភាគ (La Spychanalyse ) មកបកស្រាយបានថា ទារកវាមាន "ស្នេហា" នេះតាំងតែពីកើតមនុស្ស ។ ការដោះស្រាយពន្យល់របៀបវិទ្យាសាស្ត្រនេះ ធ្វើអោយយើងយល់បានខ្លះដែរ ។ ក៏ប៉ុន្តែការឆ្ងល់របស់យើងក៏នៅតែមានជីវិតដដែល ពីព្រោះយើងឆ្ងល់ថាហេតុដូចម្តេចក៏មនុស្សយើងកើតមាន "ស្នេហា " ជាប់មកជាមួយ ? ចុះបើកើតមកកុំសណ្តោងយក "ស្នេហា " មកជាមួយវាមិនកើតឬ ?... តើដោយបុព្វហេតុអ្វីទៅបានជាមនុស្សយើងកើតមកត្រូវតែពាំយក " ស្នេហា " មកជាមួយ ?.....

សំណួរដែលចោទឡើងទាំងប៉ុន្មាននេះ មិនមែនជាការងាយស្រួលទេ ។ ការឆ្លើយនឹងសំណួរទាំងនេះ ចេះតែមាន



www.budinst.gov.kh www.elibraryofcambodia.org

# ស្នេហានិងអក្សរសាស្ត្រ

ដូចយើងបាននិយាយរៀបរាប់រួចមកហើយថា ក្នុងសង្គមខ្មែរយើង គ្មានអ្វីដែលបញ្ជាក់ថាមានស្នេហ៍ឡើយ ។ បានជាយើង ពោលដូច្នេះ ពីព្រោះក្នុងសង្គមខ្មែរយើង គេមិននិយមឱ្យមានការទាក់ទង ឬស្រឡាញ់គ្នា រវាងស្ត្រីនិងបុរសជាមុនទេ ។ បុរសនិង ស្ត្រីរៀបយកគ្នាធ្វើជាប្ដី ប្រពន្ធ បានមិនមែនដោយសារ ចេះទាក់ ទងស្រឡាញ់គ្នាមុនទេ តែដោយទំនៀមទំលាប់ ឪពុកម្ដាយ បង ប្អូន មាមីង ជាអ្នករៀបចំផ្ដុកផ្ដាក់ចាត់ចែងឱ្យ ។ ហើយជាញឹកញាប់ ទៅទៀត គូស្រករនីមួយ ៗ ដែលត្រូវរៀបការនឹងគ្នានោះមិន ដែលបានស្គាល់មុខគ្នាទៅវិញទៅមកជាមុនដូចម្ដេចឡើយ ។ គឺ នៅពេលរៀបអាពាហ៍ពិពាហ៍នេះតែម្ដង ដែលគេបានស្គាល់បាន ឃើញមុខគ្នាជាលើកដំបូងតែម្ដង ។ ដូច្នេះអាពាហ៍ពិពាហ៍ក្នុងសង្គម ខ្មែរមិនមែនជាផ្លែផ្កាដែលចេញមកអំពីសេចក្ដីស្នេហាឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

លក្ខណៈត្រង់នេះហើយដែលបញ្ជាក់ថា សង្គមខ្មែរ ទំនៀម ទំលាប់ខ្មែរ មិននិយមនូវអ្វីដែលស្រឡាញ់ ដែលស្នេហាបេតីស្គាល់គ្នាមុនឡើយ ។ ការស្រឡាញ់គ្នាមុន ត្រូវតែផ្ដន្ទាទោសដាក់កំហុសមាក់ងាយទាបថោកថ្រៃមិនរាប់អានជាដាច់ខាត ។

ទោះបីជាសង្គមខ្មែរយើងមិននិយម ហើយផ្ដន្ទាទោសដាក់កំហុសទៅលើស្នេហាលួចលាក់ស្នេហាចិត្តនិងចិត្តជាមុននេះក៏ដោយ ក៏យើងសង្កេតឃើញថា ក្នុងសង្គមខ្មែរយើងនេះគេតែងតែជួបប្រទះនូវសេចក្ដីស្នេហាចិត្តនិងចិត្តជាមុនដែរ ។ បានសេចក្ដីថា ទំនៀមទម្លាប់មិនមែនចេះតែអាចគ្របដណ្ដប់លើផ្នត់គំនិតយុវជនខ្មែរបានគ្រប់រូបនោះទេ ។ ឯភស្តុតាងគ្រប់គ្រាន់បានបញ្ជាក់នៅក្នុងអក្សរសាស្ត្រខ្មែរជាហូរហែ តាំងតែពីដើមមកម្ល៉េះ ។

## ១. ស្នេហាក្នុងអក្សរសាស្ត្រ

ក្នុងបញ្ហាស្នេហាដែលមានលក្ខណៈចិត្ត និងចិត្តនេះ យើង

www.budinst.gov.kh www.elibraryofcambodia.org

សង្កេតឃើញ ជាអក្សរសាស្ត្រខ្មែរយើង បានបញ្ជាក់និងបានបង្ហាញយ៉ាងជ្រៅជ្រះណាស់ដែរ ។ អក្សរសាស្ត្រទោះបីមានលក្ខណៈជាព្រហ្មនិយមក្តី ជាពុទ្ធនិយមក្តី ឬ ជាខេមរនិយមក្តី សុទ្ធតែរាប់រៀបនិងអួតសរសើរអំពីស្នេហាចិត្តនិងចិត្តនេះ ។

ក្នុងរឿង "ទិព្វសង្វារ" ដែលជាអក្សរសាស្ត្រមួយក្នុងផ្នែកព្រហ្មនិយមតេបានបង្ហាញនូវតួអង្គស្តេចជាច្រើន ដែលជាអ្នកដើរលបលួចស្រឡាញ់កូនក្រមុំគេឯង ។ ការលបលួចស្រឡាញ់គ្នាមុនដោយគ្មានចាស់ទុំ ឪពុកម្តាយណាមកឃាត់នេះ តែងតែជួបនូវឧបសគ្គផ្សេងៗ ពីសំណាក់ឪពុកម្តាយបងប្អូន ។ តែទីបំផុតត្រូវបានជួបជុំគ្នា ជាគូស្វាមីភរិយាវិញដែល ។

ក្នុងរឿង "ចៅស្រទបចេក" ដែលជាអក្សរសាស្ត្រក្នុងផ្នែកពុទ្ធនិយមវិញ ក៏គេឃើញថាស្នេហាចិត្តនិងចិត្តបានត្រូវអ្នកនិពន្ធលើកយកមកអោយតម្លៃសរសើរដែរ ។

ឯក្នុងអក្សរសាស្ត្រផ្នែកខេមរនិយមទៀត បញ្ហាស្នេហាចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

និងចិត្តនេះ បានត្រូវគេលើកយកមកអធិប្បាយយ៉ាងបូរហៃ មានដូចជាក្នុងរឿង "ទុំទាវ " ជាដើម ។

រឿងរាវទាំងប៉ុន្មានក្នុងអក្សរសាស្ត្រ បានត្រូវជ្រួតជ្រាបយ៉ាងខ្លាំងក្នុងសន្ដានចិត្តប្រជាពលរដ្ឋខ្មែរ ។ អ្នកស្រុកស្រែចំការណាម្នាក់ក៏ដឹងដែរ ស្គាល់ដែររឿង "ទិព្វសង្វារ " រឿង "ចៅស្រទបចេក" រឿង "ទុំទាវ" ។ល។

រឿងទាំងនេះពិតមែនតែមានលក្ខណៈជាអក្សរសាស្ត្រដែលមាននិទ្នាការខុសគ្នា ក៏ប៉ុន្តែរឿងទាំងនេះ បានក្លាយទៅជារឿងប្រជាប្រិយ៍ដែលប្រជាកសិករខ្មែរចេះចាំទាំងអស់ ។ ផ្ទាំងអក្សរសាស្ត្រទាំងនេះ បញ្ជាក់ថា ទោះបីនៅក្នុងសតវត្សណាក៏ដោយក៏ខ្មែរតែងតែបង្កប់នូវគំនិតបដិវត្តន៍មួយ ក្នុងផ្នែកស្នេហានេះជានិច្ចដែរ ។ គេនាំគ្នាអួតសរសើរនិងអោយតម្លៃដល់ស្នេហាចិត្តនិងចិត្ត ។ ការអួតសរសើរឱ្យតម្លៃស្នេហាចិត្ត និងចិត្តនេះ គឺស្ថិតនៅត្រង់តួអង្គ ដែលមានស្នេហាចិត្តនិងចិត្តក្បត់ប្រពៃណី សុទ្ធតែជា

www.budinst.gov.kh www.elibraryofcambodia.org

តួអង្គកូនស្តេច កូនសេដ្ឋី ហើយជាពិសេសទៅទៀតគឺជាតួអង្គព្រះពោធិសត្វតែម្តង ។ ហើយទីបញ្ចប់តួអង្គទាំងនេះសុទ្ធតែជួបប្រទះទទួលនូវបុណ្យសក្តិធំដុំធ្វើជាស្តេចផែនដី ហើយបានសុភមង្គលបរិបូណ៌ទៀត ។

## ២. លក្ខណៈស្នេហាក្នុងដំណើររឿងខ្មែរ

ពិតមែនតែ ប្រជាពលរដ្ឋខ្មែរយើងភាគច្រើនមិននិយមរាប់អាននូវស្នេហាដែលមានលក្ខណៈចិត្តនិងចិត្ត ក៏យើងសង្កេតឃើញថាមានអ្នកចេះដឹងខ្មែរ អ្នកបញ្ញាវន្តខ្មែរ និយមនិងគាំទ្រដែរ ។ ការគាំទ្រនិងការនិយមចូលចិត្តស្នេហាចិត្តនិងចិត្តនេះមិនមែនទើបតែនឹងមានក្នុងពេលថ្មី ៗ នោះទេ គឺមានចាប់តាំងតែពីយូរយារណាស់មកហើយ ដូចមានបញ្ជាក់ស្រាប់នៅក្នុងអក្សរសាស្ត្រ ។

ឯជនមួយជំពូកទៀត ដែលមិនបានគាំទ្រហើយគិតតែដាក់ទោសដាក់កំហុសទៅលើស្នេហាចិត្តនិងចិត្ត ក៏បានគាំទ្របាន

www.budinst.gov.kh www.elibraryofcambodia.org

ផ្តេចផ្តើមភ្លាមដោយមិនដឹងខ្លួន ( inconsciemment ) ក្នុងរឿងស្នេហាចិត្តនិងចិត្តនេះដែរ ។ បើយើងសង្កេត នៅពេលដែលចាស់ៗ គាត់កំពុងតែស្តាប់រឿង ឬ មើលល្ខោនដែលរាប់រៀបទាក់ទងនឹងរឿងដែលនិយាយពីស្នេហាចិត្តនិងចិត្ត គាត់តែងតែស្តាប់ណាស់នូវជនណា ដែលមកពណ្ណនាតួសង្សារពីរនាក់ហើយគាត់ចង់ឱ្យតែតួរង្គឯកបានជួបជុំគ្នាជាគូស្វាមីភរិយាទៀត ។ប្រសិនបើតួឯកទាំងស្រីទាំងប្រុស ដែលលបលួចស្រឡាញ់គ្នាមុន ជួបប្រទះនូវឧបសគ្គទុក្ខភ័យអ្វីផ្សេងៗ គាត់ចាស់ៗ ក៏តាំងជួយកើតទុក្ខជួយយំ ជួយកំសត់ជាមួយមិនខានឡើយ ។

ទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់គ្រប់ជាន់ថ្នាក់ សុទ្ធតែមានផ្ទុកជាប់នូវទឹកចិត្តស្នេហាចិត្តនិងចិត្តនេះជានិច្ច ។ ទឹកចិត្តស្រឡាញ់ដោយចិត្តនិងចិត្តនេះបានដក់ជាប់ក្នុងផ្នត់គំនិត ក្នុងភាពមួយដែល "ប្រ៊ីដ" អោយឈ្មោះថា "ភាពមិនដឹងខ្លួន" ( L'Inconscient ) ។ ទឹកចិត្តស្នេហាចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

និងចិត្តដែលធ្លាក់នៅក្នុងភាពមិនដឹងខ្លួននេះគឺ មកតែអំពីសង្គមខ្មែរបានទទួលនូវការគ្របសង្កត់យ៉ាងខ្លាំង ពីសំណាក់ទំនៀមទំលាប់ដែលមានអំណាច ឥទ្ធិពលនិងអាយុជាយូរយារមកហើយប៉ុណ្ណោះ ។ ហេតុដូច្នេះហើយបានជាយើងសង្កេតឃើញថា កាលណាឱកាសល្អហុចឱ្យ ទឹកចិត្តស្នេហាចិត្តនិងចិត្តនេះដែលស្ថិតក្នុងភាពកកផ្តុំ (refoulement) ហូរចេញមកក្រៅបានដោយស្រួលមិនដឹងខ្លួន ។

ទឹកចិត្តនេះបញ្ជាក់ឱ្យយើងឃើញ ថាក្នុងសង្គមខ្មែរទំនៀមទម្លាប់បានគ្របសង្កត់លើផ្នត់គំនិត សមាជិក សង្គមជាខ្លាំង ។ ឯខ្មែរម្នាក់ ៗ ពិតមែនតែគោរពបូជាទំនៀមទម្លាប់យ៉ាងដូចម្ដេចក៏ដោយ ក៏នៅតែរក្សាទឹកចិត្តប្រឆាំង ទឹកចិត្តបដិវត្តន៍ជានិច្ចដែរ ។ ទឹកចិត្តនេះ មិនមែនមានតែក្នុងផ្នែកស្នេហាមួយមុខប៉ុណ្ណោះទេ! តែក្នុងផ្នែកដទៃទៀតក៏មានដូច្នោះដែរ ។ ដូច្នេះហើយបានជាផ្នត់គំនិតខ្មែរ មានសភាពខុសប្លែកពីជនជាតិសាសន៍ឯទៀត ។ ខ្មែរបើល្អ គឺល្អណាស់ ហើយបើអាក្រក់វិញគឺអាក្រក់ណាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ស្នេហាខ្មែរនិងល្បែងប្រជាប្រិយ៍

ដូចយើងបានរាប់រៀបជាហូរហែរមកហើយថា សង្គមខ្មែរមិននិយមមិនចូលចិត្តឱ្យមានស្នេហាចិត្តនិងចិត្ត ការលបលួចស្រឡាញ់គ្នាជាមុនឡើយ ។ នេះបើយើងពោលនិងយោលទៅតាមគោលគំនិតរបស់ទំនៀមទំលាប់ប្រពៃណីខ្មែរ ។

ក៏ប៉ុន្តែក្នុងពេលកាលសម័យជាមួយគ្នានេះ យើងក៏សង្កេតមើលទៅឃើញថាក្នុងសង្គមខ្មែរយើង បញ្ហាស្រឡាញ់គ្នាមុននេះបានត្រូវមនុស្សភាគខ្លះនិយមរាប់អានលើកស្ទួយតម្កើងណាស់ដែរ ។ ការការពារលើកស្ទួយតម្កើងនូវ ការូមរ័ក្សមេត្រីស្រឡាញ់គ្នាជាមុននេះ បានត្រូវអ្នកនិពន្ធកវីខ្មែរយើង ទាំងក្នុងសម័យបូរាណ ទាំងក្នុងសម័យថ្មី លើកយកមករៀបរាប់យ៉ាងក្បោះក្បាយ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯលក្ខណៈដែលបញ្ជាក់ថាគាំទ្រការពារនិងនិយមនូវសេចក្តីស្នេហាមិត្តនិងចិត្តនេះ មិនមែនតែមាននៅ ក្នុងអក្សរសាស្ត្រប៉ុណ្ណោះទេ សូម្បីតែក្នុងល្បែងប្រជាប្រិយ៍ទាំងឡាយ ក៏គេសង្កេតឃើញមានដែរ ។

## ១. ល្បែងប្រជាប្រិយ៍ដែលមានលក្ខណៈស្នេហា

ស្ទើរតែក្នុងគ្រប់ល្បែងប្រជាប្រិយ៍ គេសង្កេតឃើញមានបង្កប់នូវការ ការជ្រើកពង្រឹងបណ្តុះបណ្តាលនូវ ការទាក់ទងរវាងយុវនារីនិង យុវជន ហើយនិងការបើកផ្លូវឱ្យយុវជននិងយុវនារីអាចសេពគប់ស្រលាញ់គ្នាដោយចិត្តនិងចិត្តបាន ។ យើងសូមលើកយកល្បែងប្រជាប្រិយ៍ មួយចំនួនប៉ុណ្ណោះមកធ្វើអត្ថាធិប្បាយដោយឡែកៗ ដូចជាចោលឈូង, បោះអង្គុញ , ស្តេចចង់ ឬ ...ម ។ល។

ក្នុងល្បែងប្រជាប្រិយ៍ទាំងនេះ គេសង្កេតឃើញថាមានការចែកចេញជាក្រុម... ប្រុសៗ ហើយម្ខាងទៀត

www.budinst.gov.kh www.elibraryofcambodia.org

ផ្អែកស្រី ៗ ។

ក្នុងល្បែងប្រជាប្រិយ៍ចោលឈូង គឺក្មេងប្រុស១ និងក្មេងស្រី១ នាំគ្នាចោលគ្នាទៅវិញទៅមក ។ បើអ្នកណាចោលត្រូវលើសគេ អ្នកនោះត្រូវឈ្នះហើយក្រុមដែលឈ្នះនេះ អាចប្រើឱ្យក្រុមម្ខាងទៀតធ្វើអ្វីតាមក៏បានដែរ ដូចជាឱ្យអៀវ ឬច្រៀងផ្តោះផ្តងជាដើម ។

ក្នុងល្បែងចោលឈូងនេះ បើយើងសង្កេតឱ្យបានហ្មត់ចត់ និងពិនិត្យទៅតាមការវិវត្តន៍របស់ល្បែងនេះ យើងសង្កេតឃើញថាក្មេងប្រុសឬ ស្រីតែកាលណាចោលឈូងហើយ គឺតម្រង់សំដៅតែប្រុសណា ឬស្រីណាដែលខ្លួនពេញចិត្ត ។ ដូច្នេះយើងឃើញថាល្បែងចោលឈូងនេះជាឱកាសមួយ ដែលអនុញ្ញាតិឱ្យស្ត្រី និងបុរសមានការទាក់ទងគ្នាទៅវិញទៅមក ហើយអាចឆ្លៀតបញ្ចេញនូវមនោសញ្ចេតនារៀង១ខ្លួន ។

ឯល្បែងប្រជាប្រិយ៍បោះអង្គុញ ក៏មានលក្ខណៈដូច្នេះដែរគឺនៅពេលម្ខាង១ មានជ័យជំនះទៅលើគូម្ខាងទៀត គេអាចជូស

www.budinst.gov.kh www.elibraryofcambodia.org

ហូរហែមកដែរ ។ ក៏ប៉ុន្តែចម្លើយទាំងនេះពុំមានបញ្ជាក់ប្រាប់ភាពពិតនៃពាក្យ " ស្នេហា" បានឡើយ ។

ដូច្នេះពាក្យ "ស្នេហា" គ្រាន់តែបញ្ជាក់នូវភាពឥតន័យនៃស្នេហាតែប៉ុណ្ណោះ ។ ឯអត្ថន័យពាក្យ " ស្នេហា " ដែលយើងចេះតែខំបកស្រាយទាំងប៉ុន្មាន នេះគ្រាន់តែជាល្បែងកែអផ្សុកដែលយើងចេះតែខំប្រឹងអោយន័យដើម្បីនឹងកំដរជីវិតក្នុងការឆ្ពោះទៅរកស្ថានមច្ចុរាជ តែប៉ុណ្ណោះ . . . ។


មានលក់ដុំ និងរាយ នូវសៀវភៅអាន គ្រប់មុខវិជ្ជា
បារាំង, ចិន, ខ្មែរ, ថៃ, ជប៉ុន, អង់គ្លេស, ចំរៀង
KARAOKE រឿងដោយរូបភាព សៀវភៅផែមី ។ល។
១.តូបលេខ 21+22+77 ខាងត្បូងកើត
ផ្សារអូរឫស្សី Tel : 012 982 980
: 012 862 018
២.តូបលេខ 68 ផ្សារធំថ្មី Tel : 012 863 315


www.budinst.gov.kh www.elibraryofcambodia.org

បានតាមចិត្តចង់ ។ ហើយប្រុស១ ជាពិសេសមុននឹងជូសស្រី១ម្តង១ តែងតែឆ្លៀតប៉ះពាល់សាច់ទ្រលុកទ្រលន់របស់ស្រី ១ ជានិច្ច ។ ជួនកាលគេមិនព្រមអោយជូស បុរសស្ត្រីនាំគ្នារត់ប្រដេញគ្នារត់ចុះរត់ឡើងចូលពួនតាមព្រៃក៏មាន ។ ពេលនេះហើយដែលស្ត្រីនិងបុរសអាចទាក់ទង អាចស្គាល់គ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ។

ឯល្បែងប្រជាប្រិយ៍ស្តេចចង់វិញ រិតតែបកស្រាយយ៉ាងច្បាស់លាស់ទៅទៀតនូវគោលគំនិតដែលចង់ឱ្យស្ត្រី និងបុរសមានការទាក់ទងគ្នាទៅវិញទៅមក។ ក្នុងល្បែងប្រជាប្រិយ៍នេះប្រុស១ត្រូវតែទៅខ្សឹបប្រាប់អ្នកអាជ្ញាកណ្តាលម្នាក់ថា ខ្លួនស្រឡាញ់អ្នកនេះ ស្រឡាញ់អ្នកនោះ ។ ឯស្ត្រីវិញក៏មានភារៈប្រាប់ពីខ្លួនស្រឡាញ់ប្រុសនេះ កម្លោះនោះដែរ ។ កាលណាអ្នកអាជ្ញាកណ្តាលកត់សំគាល់ឃើញថា មានសាមីខ្លួនពីរនាក់មានគោលគំនិតស្រឡាញ់គ្នាទៅវិញទៅមក គេក៏ប្រកាសថា អ្នកនេះឈ្នះអ្នកនោះចាញ់ ពីព្រោះម្នាក់ថាស្រឡាញ់មុន ហើយម្នាក់ទៀត

www.budinst.gov.kh www.elibraryofcambodia.org

ថាស្រឡាញ់ក្រោយ ។ ហើយម្យ៉ាងទៀតអ្នកដែលឈ្នះត្រូវបានអ្នកចាញ់អៀវទៀត ។

ឯការទាក់ទងរវាងស្ត្រីនិងបុរស នៅពេលនេះរឹងរឹតតែមានសភាពច្បាស់លាស់ទៅទៀត ។

## ២. លក្ខណៈពិតប្រាកដនៃល្បែងប្រជាប្រិយ៍

ដូច្នេះយើងឃើញថា ល្បែងប្រជាប្រិយ៍បានបង្កប់នូវគោលគំនិតដែលចង់ធ្វើឱ្យបុរសនិងស្ត្រីមានការចេះទាក់ទងគ្នា ទៅវិញទៅមក កុំឱ្យតែឃើញ "ប្រុសឈ្មោល" ភ្លាមរត់ចូលបន្ទប់ ។ ការដែលអនុញ្ញាតិឱ្យល្បែងប្រជាប្រិយ៍ ក្លាយទៅជាល្បែងបំរាប់ទំនៀមទំលាប់នេះ រឹងរឹតតែអនុញ្ញាត្តិឱ្យការទាក់ទង រវាងស្ត្រីនិងបុរសនេះមានការទាក់ទងយ៉ាងស្រួលបួល ដោយគ្មានការកត់សំគាល់ពីចាស់ទុំប៉ុន្មានឡើយ ។

ការអនុញ្ញាតិឱ្យមានការទាក់ទងគ្នាជាមុនរវាងស្ត្រីនិងបុរសឃើញថាមានលក្ខណៈផុយស្រឡះពីប្រពៃណី ។ ការទាក់ទង

www.budinst.gov.kh www.elibraryofcambodia.org

របៀបនេះហើយដែលបណ្ដុះបណ្ដាល ឱ្យស្ត្រីនិងបុរសមានការ ដុះចិត្តស្រឡាញ់រាប់អានគ្នា ហើយក្លាយទៅជាស្នេហាចិត្តនិងចិត្ត ជាមុន ។ ការស្រឡាញ់ប្រតិព័ទ្ធគ្នាមុននេះមិនមែនជាការដែល ធ្វើឱ្យចាស់ទុំចូលចិត្តនិងពេញមុខមាត់ទេ តែនេះវាជាលទ្ធផល របស់ល្បែងប្រជាប្រិយ៍ដែលជម្រុញឱ្យក្មេង ៗ ចូលប្រកៀក ក្រកើយនៅជិតស្និទ្ធនិងគ្នាតែប៉ុណ្ណោះ ។ ក្នុងឱកាសនេះហើយ ដែលក្មេង ៗ ស្រីប្រុសនាំគ្នារង់ចាំដើម្បីនិងឆ្លៀតពេលបញ្ចេញ នូវមនោសញ្ចេតនាក្នុងដួងចិត្តផ្ទាល់ខ្លួន ។

ចុះបើសង្គមខ្មែរគោរពទៅតាមប្រពៃណី ដែលធ្លាប់តែមាន ជាលំដាប់លំដោយមក ហើយល្បែងប្រជាប្រិយ៍ដែលក្លាយខ្លួន ទៅជាទំនៀមទំលាប់មានតែជម្រុញឱ្យយុវជន ស្រីប្រុសចេះ ទាក់ទង ស្រឡាញ់គ្នាមនុស្ស ដូច្នេះ ( ដែលជាលក្ខណៈផ្ទុយនិង ) ប្រពៃណី ) តើសង្គមខ្មែរយើងមានលក្ខណៈដូចម្ដេចដែរ ?

ចុះបើស្នេហាខ្មែរមានលក្ខណៈដូច្នេះ តើយើងដែលជាខ្មែរ គួរតែអនុលោមយកលក្ខណៈណាមួយដែរ ?

www.budihst.gov.kh www.elibraryofcambodia.org

## ១១០

# ស្នេហានិងសិល្បៈ

យើងបានបើកការវែកញែកសិក្សាខ្លះៗ រួចមកហើយអំពីការទាក់ទងគ្នារវាងស្នេហានិងអក្សរសាស្ត្រ ។ ការទាក់ទងនេះបើយើងសង្កេតឱ្យបានជិតបន្តិចទៅ យើងអាចករ់សំគាល់បានទៀតថា ស្នេហារបៀបចិត្តនិងចិត្តនេះ មានលោក់ខ្លួនបំពួនអាត្មាក្នុងសិល្បៈទៀត ។ ការទាក់ទងនេះមានសភាពជិតស្និទ្ធមិនខុសប៉ុន្មានអំពីការទាក់ទងដែលមានក្នុងអក្សរសាស្ត្រឡើយ ។

### ១-ស្នេហានិងរូបចម្លាក់

ខ្មែរយើងច្រើនតែជាវិចិត្រករដ៏ចំណាន ៗ ។ ខ្មែរនិយមណាស់ខាងការឆ្លាក់ថ្មនិងគូររូបជាផ្ទាំង ។

ក្នុងចំណោមចំលាក់ផ្សេងៗ ដែលយើងសង្កេតនៅគ្រប់ទីកន្លែង ជាពិសេសនៅក្នុងប្រាសាទអង្គរ និងបន្ទាយស្រីជាដើម យើងសង្កេតឃើញមានរូបចម្លាក់អប្សរា ដែលស្អាតល្អស្រស់

www.budinst.gov.kh www.elibraryofcambodia.org

បំព្រងជានិច្ច ។ ហេតុដែលជម្រុញចិត្តមនុស្សអ្នកវិចិត្រករឱ្យកសាងឆ្លាក់នូវរូបស្ត្រីដូច្នេះ បើយើងធ្វើការត្រិះរិះទៅតាមចិត្តវិភាគ យើងឃើញថា វិចិត្រករទាំងនេះសុទ្ធតែមានសភាពខកចិត្ត (frustation) ពេញពោរក្នុងដើមទ្រូង ។ វិចិត្រករទាំងនេះខកចិត្ត ព្រោះប្រពៃណីសង្គមបានបង្ខំឱ្យយកស្ត្រីម្នាក់ដែលខ្លួនមិនស្រឡាញ់ ។ ដូច្នេះហើយបានជានៅពេលឆ្លាក់ម្តង ៗ ភាពខកចិត្តក៏ធ្លាយចេញមកលាយឡំក្នុងកិច្ចការរបស់គេ ហើយបង្ខំចិត្តឱ្យវិចិត្រករឱ្យខំបញ្ចេញស្នាដៃឆ្លាក់រូបឱ្យកាន់តែល្អប្រសើរឡើង ។ ម្យ៉ាងទៀតរូបដែលគេឆ្លាក់នេះគឺប្រព្រឹត្តិទៅតាមការស្រមៃ ទៅតាមចំណង់ផ្ទាល់របស់គេ ។ វិចិត្រករខំស្រមៃទៅរកស្ត្រីសួគិម្នាក់ដែលស្អាតស្អំល្អឥតខ្ចោះ ដែលស្ថិតនៅក្នុងភាពមួយដ៏សែនខ្ពស់ហើយមានលក្ខណៈជាពិសិដ្ឋ (le sacré ) ទៅទៀត ។

ដូច្នេះរូបចម្លាក់ទាំងនេះ ជាកញ្ចក់មួយដែលឆ្លុះបញ្ចាំងនូវ

www.budinst.gov.kh www.elibraryofcambodia.org

ទឹកចិត្តរបស់វិចិត្រករខ្មែរដែលប្រាថ្នានូវស្នេហាមួយ ដែលមានលក្ខណៈស្អាតស្អំបរិសុទ្ធ ដែលស្ថិតនៅក្នុងការដ៏សែនខ្ពស់មួយ ។

## ២-ស្នេហានិងបទភ្លេងចម្រៀងខ្មែរ

ដើម្បីនឹងបញ្ចេញបញ្ជាក់នូវទំហំទឹកចិត្តដែលត្រូវការចង់បានផងប្រាថ្នានូវស្នេហា ដែលមានលក្ខណៈស្អាតស្អំល្អបរិសុទ្ធនេះ ខ្មែរយើងបានរិះរកបទចម្រៀងណាមួយទៀត ដើម្បីតស៊ូប្រឆាំងនឹងច្បាប់ទម្លាប់ប្រពៃណីរបស់សង្គម ។ បទចម្រៀងថ្មីនេះគឺបទភ្លេងតន្ត្រី ។ តន្ត្រីខ្មែរគ្មានលក្ខណៈអ្វីដែលក្ដុងក្ដាំងផ្ទុះអឺងកងឡើយ ។ តែតន្ត្រីខ្មែរបើស្ដាប់ទៅឮសូររងំពិរោះលន្លង់អន្លោច ស្ដាប់យូរៗទៅរិតតែពិរោះ ហើយរិតតែកំសត់ឡើងថែមទៀត ។ ភ្លេងខ្មែរដែលមានលក្ខណៈលន្លង់លន្លោចដូច្នេះ គួសបញ្ជាក់យ៉ាងច្បាស់នូវទឹកចិត្តមនោសញ្ចេតនា (sentimental) អណ្ដែតអណ្ដូងរបស់ខ្មែរ ។ ភ្លេងខ្មែរដែលឮសូររងំនេះបំពេរអារម្មណ៍នឹងលួង

www.budinst.gov.kh www.elibraryofcambodia.org

លោតបេះដូងប្រចាំរបស់ពុទ្ធជនខ្មែរ ដែលត្រូវប្រេះឆរដោយស្ថានការណ៍ប្រវត្តិរបស់សង្គមជាតិ ។ បទភ្លេងខ្មែរពោលត្រដាងយ៉ាងពិតប្រាកដនូវដង្ហើមរបស់វិញ្ញាណមនុស្សមួយក្រុម ដែលត្រូវគេជិះជាន់សង្កត់សង្កិន ។ វាជាទំនួញស្រែកថ្ងូររបស់អ្នកតូចតាចដែលកំពុងតែជួបប្រទះនូវទុក្ខវេទនាគ្រប់បែបយ៉ាង និងជាសម្លេងដែលស្រែកអង្វរឱ្យក្រោកតស៊ូ កុំបណ្តែតបណ្តោយ ។

ភ្លេងខ្មែរដែលជាទំនួញស្រែកថ្ងូររបស់វិញ្ញាណទន់ខ្សោយបានក្លាយទៅជាភ្លេងប្រពៃណី ដែលគេនិយមក្នុងពេលរៀបអាពាហ៍ពិពាហ៍ទៀត ។

ហើយជាពិសេសទៅទៀត ក្នុងបទភ្លេងខ្មែរយើងគេតែងតែនិយមរៀបចំតែងជាចម្រៀងពិរោះដែលមានន័យទួញទោយ ហើយទាក់ទងនឹងបញ្ហាស្នេហាជានិច្ច ។ ចម្រៀងនីមួយ ៗ ដូចជា "ផ្គរលាន់" , "កន្សែងសូត្រ" , "កន្សែងក្រហម" , "ព្រពាំងពាយ" , "រង្សុំក្អែក" ជាដើម ។ល។ សុទ្ធតែ

www.budinst.gov.kh www.elibraryofcambodia.org

ជាបទដែលអង្វរកនិងបំពេរសុំសេចក្ដីស្នេហាពីស្រី ។ ដូច្នេះ ចម្រៀងទាំងនេះសុទ្ធតែជាចម្រៀងស្នេហា ដែលប្រុស ។ ផ្ដោះផ្ដងទៅឱ្យស្រី ។ ដូច្នេះ បទភ្លេងចម្រៀងដែលលើកស្ទួយតម្លើងនិងដង្ហើយរឿងស្នេហា ថាបទភ្លេងចម្រៀងដែលផុយស្រឡះពីប្រពៃណី ។ លក្ខណៈនេះបញ្ជាក់ឱ្យយើងយល់បាន ថាការតស៊ូរបស់ស្នេហាមាននៅគ្រប់វិស័យ ទោះបីក្នុងវិស័យបទចម្រៀងភ្លេងតូរ្យតន្ត្រីក៏ដោយ ។

ដូច្នេះក្នុងសិល្បៈ យើងក៏ឃើញថាស្នេហាចិត្តនិងចិត្តក៏មានសកម្មភាពយ៉ាងខ្លាំងក្លា ហើយបានផ្ដោតជាប់ក្នុងគោលគំនិតរបស់ប្រជាពលរដ្ឋខ្មែរ ។ អ្នកបដិវត្តន៍ក្នុងសម័យចាស់មានគំនិតជ្រៅជ្រះណាស់ ក្នុងការរកមធ្យោបាយដូចជាយកសិល្បៈជាដើមសំរាប់ធ្វើជាឧបករណ៍ផ្សាយនូវគោលគំនិតតស៊ូ ។ ដូច្នេះការតស៊ូនេះមាននៅគ្រប់វិស័យ ហើយគ្មានលក្ខណៈអ្វីធ្វើឱ្យគេភ្ញាក់ផ្អើលទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ហាអាពាហ៍ពិពាហ៍

# ក្នុងសង្គមខ្មែរ

អាពាហ៍ពិពាហ៍ ជាបញ្ហាមួយយ៉ាងសំខាន់ និងជាបញ្ហាយ៉ាងស្មុកស្មាញបំផុត ក្នុងជីវិតមនុស្សលោក ។ យុវជននិង យុវតីពេលដែលចាប់ចិត្តប្រតិព័ទ្ធ ស្រឡាញ់គ្នា ទៅវិញទៅមក តែងតែមានគំនិតនឹកគិតថា "យើងត្រូវតែរស់នៅរួមសុខ រួមទុក្ខជាមួយគ្នាលុះត្រាអវសានជីវិត" ។ ដើម្បីរួមរស់នៅក្រោមដំបូលមួយជាមួយគ្នា គូសង្សារទាំងពីរត្រូវតែរៀបអាពាហ៍ពិពាហ៍តាមច្បាប់និងតាមប្រពៃណីជាមុនផង ។ បើមិនដូច្នោះទេ គូស្នេហាទាំងពីរនេះ នឹងត្រូវគេចាត់ទុកថាគ្មានខាន់ស្លា ហើយគូស្វាមីភរិយានេះ ត្រូវគេទុកដូចជាមនុស្សរស់នៅក្រៅសង្គមជាតិខ្មែរដូច្នេះដែរ ។ ដូច្នេះជាចាំបាច់ តែត្រូវតែគោរពប្រពៃណី (រៀបការតាមប្រពៃណី) ។ហើយជាពិសេសទៅទៀតប្រពៃណីខ្មែរ

www.budinst.gov.kh www.elibraryofcambodia.org

មិនអនុញ្ញាតឱ្យកុលបុត្រកុលធីតា ស្នេហាបានខ្លួនប្រាណជាមុន ហើយទើបរៀបការជាក្រោយឡើយ ។ អ្នកណាក្បត់ប្រពៃណីក្រុមគ្រួសារមិនរាប់រកទេ ។ តែបើគេរាប់រកវិញ ក៏ដោយក៏គ្រាន់តែជាការទើសទាល់ ឬ គ្រាន់តែជាការបង្គ្រប់ៗ ដោយសារតែជាប់សាច់ញាតិប៉ុណ្ណោះ ។

ចំពោះការរើសគូស្រករវិញ សាមីខ្លួនប្រុសស្រីគ្មាន ឥស្សរភាពពេញលេញ ដើម្បីសម្រេចតាមចិត្តខ្លួនឡើយ គឺថា ភារៈនេះស្រេចទៅលើចាស់ទុំជាមាតាបិតា ឬអាណាព្យាបាលជាអ្នកសម្រេច ពីព្រោះគេផ្តេកផ្តួលទៅតាមពាក្យថា "ទំមិនដែលធំជាងនាឡិ" ។

ក្នុងសម័យលូតលាស់នៃវិទ្យាសាស្ត្រនេះគេឃើញថាយុវជនយុវតីដែលស្រឡាញ់គ្នាមុន ទើបបានគិតគូររៀបអាពាហ៍ពិពាហ៍ជាក្រោយមានច្រើនណាស់ ។ ក៏ប៉ុន្តែភាគច្រើននៃស្នេហារបៀបនេះក្នុងសង្គមខ្មែរ មិនសូវមានលទ្ធភាពបានស្របតាមបំណងទេ

www.budinst.gov.kh www.elibraryofcambodia.org

៩

# ទស្សនវិទូនិងស្នេហា

ចំពោះមនុស្សជាតិជំនាន់ដើម (ជំនាន់មុនប្រវត្តិសាស្ត្រ) ពិភពលោកយើងនេះ ជាពិភពលោកគ្មានអទីទេព គឺជាពិភពមួយស្ងាត់ជ្រងំហើយស្ថិតនៅក្នុងសភាពងងឹតឥតដំណើង ។ ក្រោយមកចំពោះភ្នែកទស្សនវិជ្ជា ដែលមានជំនឿជឿជាក់លើព្រះអាទីទេព ពិភពលោកក៏ប្រែក្លាយជាពិភពមួយ ដែលពោរពេញទៅដោយអាទីទេព ។ ពិភពលោកសុទ្ធតែជាទឹកដៃ ជាស្នាមព្រះហស្ថរបស់អាទីទេព ។ ទីបំផុត ចំពោះភ្នែកអ្នកប្រាជ្ញវិទ្យាសាស្ត្រវិញ ពិភពលោកនេះជាពិភពរបស់របរ ( Le monde des choses) ជាពិភពមួយដែលពោរពេញទៅដោយរបស់របរផ្សេង ៗ ។

តែទោះបីជាយ៉ាងណាក៏ដោយ ពិភពលោកនេះស្ថិតនៅជានិច្ចជាពិភពទាក់ទង ( un monde de relation ) ដែលមនុស្ស

www.budinst.gov.kh www.elibraryofcambodia.org

ផុតសាមីខ្លួនច្រើនតែបែរទៅ ជារឿងអាពាហ៍ពិពាហ៍ជាមួយបុរស ឬ នារីផ្សេងទៀតវិញដោយសារការប្រែប្រួលចិត្តគំនិតរបស់សាមីខ្លួន ឬក៏ដោយគ្រួសារបង្ខិតបង្ខំ ។

មួយវិញទៀត អាពាហ៍ពិពាហ៍ដែលចាស់ៗ (អ្នកដែលមានគំនិតបរមបូរាណ) ចូលចិត្តជាងគេ គឺរៀបការរបៀបឱ្យបានចំណេញ គឺធ្វើដូចម្តេចឱ្យតែបានលុយកាក់ ទ្រព្យសម្បត្តិ និងយសសក្តិ ។ ឯបញ្ហាថាតើថ្ងៃក្រោយទៅបានសុខសប្បាយឬបានទុក្ខដោយសារការទាស់ទែងខ្វែងគំនិតគ្នា គេពុំសូវគិតដល់ឡើយ ។ គំនិតបែបនេះ អ្នកដែលមានសញ្ញាប័ត្រធុនល្មម ៗ ក៏រមែងបែកប្រាណេភ្លាម ៗ ដែរ ថាកាលណាបើរៀបការជាមួយអ្នកណាមានគេនិងមានសម្បត្តិទ្រព្យស្រាប់ មិនបាច់ព្រួយរកស៊ីលំបាកទៅអនាគត ។ ខ្លះទៀតគេស្វែងរកខាងបក្សពួក "ប៉ារទី" (parti) ដើម្បីថ្ងៃក្រោយទៅគេនិងបានបុណ្យ បានសក្តិបានធ្វើធំ បានធ្វើកុងស៊ីយ៍ . . . ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ យើងឃើញថា សម័យមុនក៏ដូចជាសម័យនេះដែរ គេច្រើនសម្លឹងឃើញទៅលើទ្រព្យសម្បត្តិ ពូជពង្សវង្សត្រកូលជាបឋម ឯការរៀបអាពាហ៍ពិពាហ៍តាមចិត្តដែលស្រីប្រុសស្រឡាញ់គ្នាទោះល្មួចលាក់ក្តី ដោយចំហក្តី ដូចជាមិនសូវមានទៅវិញ ។ គឺរបៀបដូចពោលមកនេះឯង ដែលបញ្ជាក់ឱ្យឃើញថាអាពាហ៍ពិពាហ៍គ្មានតម្លៃត្រង់ណាដែលស្មោះត្រង់ទៅតាមផ្នត់គំនិតចេតនាស្នេហាពិតប្រាកដនៃមនុស្សម្នាក់ ៗ នោះឡើយ ។ ការរៀបអាពាហ៍ពិពាហ៍ក៏ក្លាយទៅជា " គុកត្រា " រវាងមនុស្សពីរនាក់ទៅវិញហើយជាពិសេសទៅទៀត អាពាហ៍ពិពាហ៍នេះ គឺជាល្បែងកែអផ្សុក ឬក៏ជាល្បែងឥតន័យរបស់មនុស្សលោកតែប៉ុណ្ណោះ ។

ចុះបើមនុស្សម្នាក់ៗ រៀបការ គិតតែពីរឿងបានលុយកាក់ប្រាក់កាស និងបុណ្យសក្តិ តើស្រីៗ ដែលជាកូនអ្នកក្រ និងទៅជាយ៉ាងណាដែរ ? ហើយបើស្រីៗ ខ្លះស្វែងរកតែប្រុស ៗ

www.budinst.gov.kh www.elibraryofcambodia.org

ដែលមានសញ្ញាប័ត្រធំ តើប្រុសៗ ដែលឥតសញ្ញាប័ត្រសោះ នឹងទៅជាយ៉ាងណាដែរ ?

នេះហើយគឺជាការវិវត្តន៍នៃសង្គមមនុស្ស ។ មនុស្សលោក មិនសូវបានគិតនិងគោរពឧត្តមគតិរបស់ខ្លួនប៉ុន្មានទេ តែបោក ប្រាស់កុហកតែខ្លួនឯង ។ មនុស្សម្នាក់ៗ ឱ្យតែឃើញប្រាក់ ឃើញទ្រព្យ ឃើញបុណ្យសក្តិ ឃើញបក្សពួកផង រមែងខំត្បុល ត្រសុលទៅរកដោយឥតអៀនខ្មាស ឥតគិតថាខ្លួនត្រូវគោរព ឧត្តមគតិ ឬទ្រឹស្តីអ្វីឡើយ ។ បញ្ហាធំ គឺបញ្ហាលុយ បញ្ហា ទ្រព្យសម្បត្តិ ទោះបីលុយកាក់ ទ្រព្យសម្បត្តិនោះនាំមកនូវ សេចក្តីទុក្ខលំបាកក្តៅក្រហាយទៅថ្ងៃក្រោយក៏ដោយ ។ ឯ អាពាហ៍ពិពាហ៍ក្នុងសង្គមខ្មែរយើងសព្វថ្ងៃគឺ **ជាការប្តូរផល ប្រយោជន៍ខាងផ្លូវសម្ភារៈប៉ុណ្ណោះ** ។

**ដូច្នេះ អាពាហ៍ពិពាហ៍របៀបនេះមានន័យដូចម្តេចដែរ ?**

www.budinst.gov.kh www.elibraryofcambodia.org

# យោបល់រួម

ការសិក្សាស្រាវជ្រាវរបស់យើងដែលធ្វើទៅដោយសង្ខេបក្នុងផ្នែក "ស្នេហាខ្មែរ" នេះបានបញ្ជាក់និងបង្ហាញឱ្យយើងឃើញថាក្នុងសង្គម ខ្មែរយើង តាំងតែពីពេលណាពីពេលណាមក មានស្នេហាពីរបែបដែលមានលក្ខណៈផ្ទុយស្រឡះពីគ្នា ។

ស្នេហាទីមួយ គឺស្នេហាដែលផុសដោយជីវិតមនុស្ស ផុសដោយធម្មជាតិពិតៗ ពុំ គឺស្នេហាដែលផុសទៅតាមលក្ខណៈរបស់ប្រពៃណី ។ ឯស្នេហាមួយទៀត គឺស្នេហាផ្សំផ្គុំ ដែលកើតតែពីការរៀបចំរបស់ឪពុកម្ដាយដើម្បីមិនឲ្យប្រាសចាកការប្រព្រឹត្តរបស់ប្រពៃណី ។

បើយើងពោលទៅតាមលក្ខណៈប្រពៃណីទំនៀមចុះសម្រុង របស់ស្នេហាទាំងពីរបែបនេះមក យើងឃើញថាក្នុងសង្គមខ្មែរយើងតាំងតែពីបុរាណរៀងរហូតមក តែងតែមានកម្លាំងពីរប្រឆាំងប្រជែងគ្នា ។ កម្លាំងទាំងពីរនេះ គឺកម្លាំងពួកអ្នកជំនាន់មុននិងកម្លាំងប្រជារាស្ត្រដែលមានសភាពទន់ខ្សោយ ។

ពួកអ្នកជំនាន់ដើមធ្វើឲ្យកូនចៅរបស់ខ្លួន និងក្រុមគ្រួសារពួកគេតែងតែយក

www.budinst.gov.kh www.elibraryofcambodia.org

ប្រពៃណីចាស់ៗដែល មកធ្វើជាទម្ងន់សំរាប់សង្កត់សង្កិនចិត្តគំនិតសេរីភាពរបស់ប្រជាជនតូចតាច ។

ដូច្នេះយើងឃើញថា ការតស៊ូរបស់វណ្ណៈប្រជាពលរដ្ឋកសិករទន់ខ្សោយពួកនោះមានមកជាហូរហែ ។ ហើយការប្រយុទ្ធតស៊ូជានិច្ចនេះ បានតាបទ្រឹស្តីតាមគោលគំនិតទៀត ។

ម្យ៉ាងវិញទៀត យើងស្គាល់និងដឹងបានទៀតថា ទឹកចិត្តនិងផ្នត់គំនិតខ្មែរតែងតែមានបង្កប់នូវលក្ខណៈតស៊ូប្រឆាំងជានិច្ចដែរ ។ ប៉ុន្តែដោយសារ ការគាបសង្កត់របស់សង្គម (pression sociale) ខ្លាំងពេកទឹកចិត្តតស៊ូប្រឆាំងនេះ ក៏លាក់ខ្លួនសម្ងំក្នុងភាពមិនដឹងខ្លួន (L'inconscient) " ។ ដូច្នេះបើមានតែកត្តាអ្វីមួយដែលអាចឆ្កឹះកកាយឱ្យចំចំណុចបន្តិច នោះទឹកចិត្តខ្មែរនឹងពុះកញ្ជ្រោលប្រឆាំងតស៊ូភ្លាមជាមិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

១២២

# បញ្ជីអត្ថបទ


| | | |
|---|---|---|
| អារម្ភកថា | ទំព័រ | ១ |


## ជំពូកទី១


| | | |
|---|---|---|
| ស្នេហាជាអ្វី ? | ទំព័រ | ៤ |
| ទស្សនវិទូនិងស្នេហា | - | ៩ |
| ភ្លើងកាមតម្រេក | - | ២០ |
| បញ្ហាស្នេហា | - | ២៦ |


## ជំពូកទី២


| | | |
|---|---|---|
| កាមតម្រេក | ទំព័រ | ៣៦ |
| លក្ខណៈស្នេហា | - | ៤៣ |
| ជនដែលមានស្នេហា | - | ៤៨ |
| ទិដ្ឋភាពស្នេហា | - | ៥៩ |
| ការវិវត្តន៍នៃសេចក្ដីស្នេហា | - | ៦៩ |


www.budinst.gov.kh www.elibraryofcambodia.org

លោកទាំងអស់សុទ្ធតែមានការទាក់ទងឆ្លងឆ្លើយគ្នាទៅវិញទៅមក ។ ការទាក់ទងរវាងគ្នានឹងគ្នានេះបង្កើតជាចំណងមួយដែលគេហៅថា "ស្នេហា" ។

មានតែជនវិកលនេះ (l' béné ) ដែលគ្មានការទាក់ទងនឹងមនុស្សដូចគ្នា ។ ជនវិកលនេះត្រូវបាត់បង់អស់នូវអ្វីដែលហៅថា "ស្នេហា" ហើយគេក៏គ្មានការទាក់ទងអ្វីជាមួយនឹង ខ្លួនគេដែរ ។

ដូច្នេះកាលណាមានជីវិត គឺមានស្នេហា (êve c'est aimer ) ។

សេចក្តីស្នេហានេះមិនមែនមានសភាពលក្ខណៈដូចគ្នានោះទេ ។ ស្នេហានេះមានសភាពផ្លាស់ប្តូរទៅតាមការរិះគិតពិចារណាទៅតាមប្រាជ្ញា ( Liete l gence ) និងការចេះដឹង ( Le saveir ) របស់មនុស្សម្នាក់ៗ ។

នៅជាន់ក្រោមបំផុត សេចក្តីស្នេហាស្ថិតនៅលើសមូស្ស

www.budinst.gov.kh www.elibraryofcambodia.org

រាងកាយ (La beauté du corps) ។ ដំបូងបើខ្ញុំចាប់ចិត្តស្រឡាញ់ប្រតិពទ្ធ័នរណាម្នាក់ គឺដោយខ្ញុំយល់និងបានឃើញថា អ្នកនោះ នាងនោះ ស្អាតស្រស់សោភាគួរឱ្យបេតី ។ សម្រស់សម្ផស្សឆើតឆាយនេះហើយ ដែលទាក់ទាញអារម្មណ៍ខ្ញុំឱ្យផ្តោតបាញ់ឆ្ពោះទៅរកតែលើរូបនាងនោះ ។ សម្រស់នេះចូលតាមភ្នែក ហើយក៏ត្រូវបានចាក់ឫសគល់ក្នុងបេះដូងរបស់ខ្ញុំ ។ អារម្មណ៍ខ្ញុំលែងនឹងនរ ចេះតែករម្រើករំភើបមិនចេះចប់ហាក់ដូចជាស្រេកឃ្លានន្ទូវអ្វីមួយដែលខ្ញុំពុំដឹងជាឱ្យឈ្មោះថាដូចម្តេច ។ ក្រុងត្រុឌដែលចាប់ចិត្តស្នេហានាងកាគី ខំធ្វើព្យុះធ្វើភ្លៀងធ្វើផ្គរខំឆ្លងកាត់ឧបសគ្គគ្រប់បែបយ៉ាង ក៏ដោយសារតែសម្ផស្សដ៏ផូរផង់ឥតខ្ចោះរបស់នាងកាគី ។

ឯទុំដែលបានចាប់ចិត្តនឹករឭកស្រឡាញ់ទាវ ខំសឹកខុសក្រឹត្យវិន័យក៏ដើម្បីឱ្យបានមកមើលវង់ភក្ត្រនាងដែរ ។ តើនេះមិនមែនដោយសារសម្រស់ឆើតឆាយនៃរាងកាយនាងទាវទេឬ? គ្រាន់តែក្រឡេកឃើញនាងទាវឆើតកភ្លាមកាលណា នេនទុំក៏

www.budinst.gov.kh www.elibraryofcambodia.org

## ១២

ចាប់ចិត្តស្រឡាញ់ ចាប់ផ្តើមស្រមៃ ចាប់ផ្តើមរវើរវាយទៅឆ្ងាយស្រេចទៅហើយ ។

តែសេចក្តីស្នេហានេះ មិនមែនស្ថិតនៅលើសម្ផស្សរាងកាយប៉ុណ្ណោះទេ ។ ជំហានទីពីរ សេចក្តីស្នេហានេះត្រូវស្ថិតនៅលើចិត្តគំនិតនិងអាត្មនស្អាតស្អំ ( La beaute de l'âme) របស់នាងដែលខ្ញុំស្រឡាញ់ ។ បើសិនជានាងនោះមានរូបរាងស្អាតបាតដល់ណាក៏ដោយ តែបើបែរជានារីវិកលចរិតទៅវិញ នោះខ្ញុំក៏ពុំអាចទ្រាំទ្រស្នេហានាងតទៅទៀតបានដែរ ។

ខ្ញុំអាចស្រឡាញ់នាងនោះបាន លុះត្រាតែនាងនោះមានចិត្តស្អាតស្អំ ស្មោះត្រង់និងខ្ញុំ ។ បើនាងនោះមានចិត្តវៀចវេរម្តងទៅលិចម្តងទៅកើត នោះស្នេហារបស់ខ្ញុំចំពោះនាងក៏គ្មានសារៈសំខាន់អ្វីដែរ ។

ក្រុងគ្រុឌដែលលះបង់នាងកាកីចោល ហើយយកមកប្រគល់ថ្វាយស្តេចព្រហ្មទត្តវិញ ក៏ដោយយល់ឃើញថានាងកាកី

www.budinst.gov.kh www.elibraryofcambodia.org

នេះមានគំនិតមានអាត្ម័នទនិងមានអារម្មណ៍មិននឹងនរមិនស្អាតស្អំ មិនស្មោះត្រង់និងចិត្តភក្តីរបស់ខ្លួនឡើយ ។

ឯព្រះបាទព្រហ្មទត្ត ដែលបំបរបង់នាងកាកីចោលទៅទៀតនោះ ក៏ដោយសារតែយល់ដូចក្រុងគ្រុឌដែរ ។ ខ្ញុំដែលសុខចិត្តបូជាកម្លាំងកាយ ដើម្បីនាងទាវមិនខ្លាចស្លាប់ ក៏ព្រោះតែយល់ឃើញយ៉ាងច្បាស់ដែរថា នាងទាវមានចិត្តស្អាតស្អំបរិសុទ្ធចំពោះតែលើរូបខ្លួនមួយ ។

ស្នេហាដែលស្ថិតនៅលើ សម្រស់ចិត្តគំនិតស្អាតស្អំនេះ ទាក់ជាប់ជាមួយនឹងអំពើល្អ ( Les bonnes actions ) ដូចជាបាតដៃនឹងខ្នងដៃ ។ កាលណាចិត្តគំនិតយើងស្អាតស្អំហើយអំពើរបស់យើងទាំងប៉ុន្មាន ក៏បាញ់តម្រង់ឆ្ពោះទៅរកសេចក្តីល្អដែលអំពើល្អនេះជាលទ្ធផលដែលក្លាយចេញមកពីចិត្តគំនិតល្អប្រពៃ។ ដូច្នេះកាលណាគូរស្នេហារបស់យើងបានបញ្ចេញសកម្មភាពមួយយ៉ាងប្រសើរគាប់ចិត្ត ពេលនោះយើងរីកថ្លើមប្រមាត់សប្បាយ

www.budinst.gov.kh www.elibraryofcambodia.org

រីករាយ ហើយយើងក៏រិតស្រឡាញ់គូសង្សារយើងទ្វេឡើងទៀត ។ ដោយសារតែទំស្មោះត្រង់និងខ្លួនសុខចិត្តវេទនាសុខចិត្តប្រថុយជីវិតដើម្បីសេចក្ដីស្នេហា ដោយមិនព្រមខ្លាចអំណាចចក្រពត្តិរបស់ព្រះរាជា ទើបបានជានាងទាវហ៊ានឆ្លើយទូលប្រាប់ស្ដេចដោយមិនបាច់គិត ថា ពិតជាប្រពន្ធម៉ឺនទំមែន !...

រីឯលក្ខណៈស្នេហាពិតប្រាកដរបស់ទស្សនវិទូវិញ មិនមែនស្ថិតនៅលើក្របខ័ណ្ឌស្នេហាទាំងនោះទេ ! ... ទស្សនវិទូជាអ្នកដែលបានឆ្លងកាត់ផុតលក្ខណៈស្នេហាធម្មតាទាំងបីខាងលើនេះរួចស្រេចទៅហើយ ។

ស្នេហារបស់ទស្សនវិទូ មិនមែនស្ថិតនៅក្នុងពិភពអារម្មណ៍ ( **le monde sensible**) នេះទេ ។

ស្នេហារបស់ទស្សនវិទូ គឺស្ថិតជំពាក់ទៅលើពិភពគតិ ( **le monde intell gible** ) ។ សេចក្ដីស្នេហានេះ គឺជាសេចក្ដីស្នេហាលើសោភ័ណអមតៈ ( **l'amort du beau en soi** ) ។

www.budinst.gov.kh www.elibraryofcambodia.org

ទស្សនវិទូយល់ថា    អាត្មានរបស់យើងដែលវិលវល់ក្នុងវាលវដ្ត សង្សារនេះ មានការឈឺចាប់យ៉ាងខ្លាំង ហើយអាត្មាននេះត្រូវការ ជាចាំបាច់ក្នុងការស្វះស្វែងរកនូវការស្ងប់ស្ងាត់ រកពិភពគតិមួយ ដែលអាចផ្តល់មកវិញ នូវសម្រស់គ្រប់បែបយ៉ាង ។

ដូច្នេះទស្សនវិទូ ជាជនមានស្នេហាមួយរូប ( un amoureux ) ដែលគួចចិត្តចង់បានតែសោភ័ណអមតៈ ( le beau en soi ) ។ ទស្សនវិទូជាស្មូមយាចកកំសត់ក្រតោកយ៉ាកម្នាក់ដែលខំដើរសុំ ទានស្វះស្វែងរកនូវពុទ្ធិ ( la sagesse ) ។ ពុទ្ធិនេះជាប្រភពនៃ សេចក្តីសំបូណិសប្បាយគ្រប់បែបយ៉ាង ។ ដូចនេះ ស្នេហា របស់ទស្សនវិទូ    ជាស្នេហាមួយដែលខំធ្វើដំណើរពីការក្រីក្រ លំបាកល្ងង់ខ្លៅ ឆ្ពោះទៅរកការចេះដឹង ទៅរកសម្រស់អមតៈ ដែលជាប្រភពនៃការសម្បូណិសប្បាយ ។

នាងទាវដែលសម្លាប់ខ្លួនទៅតាមទុំនេះ ក៏ដោយយល់ឃើញ ថាក្នុងពិភពយើងសព្វថ្ងៃនេះ គេពុំអាចរកស្នេហាពិតៗ មែនទែន

www.budinst.gov.kh www.elibraryofcambodia.org

បានទេ ។ ភាពស្នេហាទាំងប៉ុន្មានដែលមាននៅក្នុងពិភពលោកយើងនេះ សឹងសុទ្ធតែជាស្នេហាបោកបញ្ឆោតគ្មានការពិតអ្វីទាំងអស់ (des illustions perdues) ។ ឯសភាពពិតប្រាកដមែន ៗ គឺស្ថិតនៅក្នុងពិភពមួយទៀត គឺពិភពគតិ ។ ក្នុងពិភពគតិនេះហើយដែលនាងទាវអាចត្រេបរស់ជាតិស្នេហាពិតប្រាកដ (Le vrai amour) ជាមួយទុំដោយគ្មានព្រួយបារម្ភ ដោយគ្មានភ័យថាមានអ្នកណាមកឈ្នានិសតទៅទៀតបានឡើយ ។

ដូច្នេះតើទស្សនវិទូអាចនឹងចាប់យកសោភ័ណស្នេហាអមតៈ (L'amour du beau en soi) បានឬទេ ? . . .

ទោះបីទស្សនវិទូខំប្រឹងស្វះស្វែងយ៉ាងណាក៏ដោយ ក៏គេពុំអាចនិងរកសម្រស់ស្នេហាអមតៈនេះបានដែរ ។ ជនណាដែលមានស្នេហា ជននោះតែងតែយកត់សំគាល់ឃើញថាខ្លួនគេចេះតែមិនគ្រប់គ្រាន់ ចេះតែខ្វះជានិច្ច ។ ដូច្នេះស្នេហាត្រូវការការគ្រប់គ្រាន់ពេញលេញមិនខ្វះខាត ។ តែចំពោះមនុស្សយើង

www.budinst.gov.kh www.elibraryofcambodia.org

០៨៦.១២២

រស់ ចន្ត្រាបុត្រ
បរិញ្ញាប័ត្រ ផ្នែកទស្សនវិជ្ជា
អតីត និស្សិត គរុកោសល្យជាន់ខ្ពស់

# អំពីស្នេហា

# DE L'AMOUR

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៦៩២៩/០៣

ការផ្សាយរបស់សារពត៌មាន “ចយាជន”

រក្សាសិទ្ធិ

បោះពុម្ពលើកទី ១

ព.ស ២៥១៥ គ.ស ១៩៧០

www.budinst.gov.kh www.elibraryofcambodia.org

ស្នេហានេះនៅតែមិនស្លាប់ជាដរាប ។ ឯការដែលខ្ញុំតាមស្រឡាញ់អ្នកនេះ តាមស្រឡាញ់អ្នកនោះ មិនចេះសំរាក មិនចេះនឿយណាយ មិនមែនបានសេចក្តីថាខ្ញុំខូចខិលឬអាក្រក់អាក្រីគ្មានសីលធម៌ក្នុងខ្លួនសោះនោះទេ !. . . តែនេះមកពីខ្ញុំគ្មានលទ្ធភាព និងក្តោបចាប់យកសម្រស់ស្នេហាអមតៈនេះបាន. . . . ដែលខ្ញុំខំត្រេចរស្កាត់រត់ខិតតាមសេចក្តីស្នេហានេះ មកអំពីខ្ញុំស្រវាចាប់ស្នេហាមិនបាន ។ ម្យ៉ាងវិញទៀត ការដែលខ្ញុំរត់តាមស្នេហានេះ មកពីខ្ញុំយល់ថា បើខ្ញុំអាចយកស្នេហាបាន ស្នេហានេះអាចកំចាត់លែងអោយខ្ញុំមានស្នេហាមានកាមតម្រេកតទៅទៀត ។ ឯការដែលខ្ញុំពុំអាចចាប់ឈោងយកស្នេហាបាន គឺមកពីស្នេហានេះជាស្រមោលគ្រាប៉ុណ្ណោះ ។ តែទីបំផុតសេចក្តីស្នេហានេះនៅតែមិនចេះស្លាប់ ឯចិត្តខ្ញុំសោតក៏មិនស្លាប់ ។ ដូច្នេះ សេចក្តីស្នេហាត្រូវស្ថិតនៅលើភាពសូន្យទទេ ។ ហើយសេចក្តីស្នេហារបស់



www.budinst.gov.kh www.elibraryofcambodia.org

មនុស្សយើងក៏ជាស្នេហាមួយឥតប្រយោជន៍ដែរ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សេចក្តីស្នេហានេះ មិនមែនស្ថិតនៅលើការសង្កេត ការជាប់ជំពាក់ចិត្តលើរបស់ដ៏មានតម្លៃមួយនោះទេ !. . . ស្នេហាជាចលនាមួយដែលចេះតែធ្វើដំណើរលូតខ្ពស់កើនឡើងជាលំដាប់ពីសភាពទាបអន់ថយទៅរកសភាពមានតម្លៃ ( La valeur ) មួយដែលចេះតែខ្ពស់ឡើងជាលំដាប់ ។ សេចក្តីស្នេហាមិនមែនធ្វើអោយយើងខ្វាក់នោះទេ ។ សេចក្តីស្នេហានេះអាចបើកភ្នែកអោយយើងមើលតម្លៃអ្វីៗឃើញយ៉ាងច្បាស់ពិតប្រាកដនៅពេលដែលយើងបិទភ្នែកជិត ។ បានសេចក្តីថា ស្នេហាមិនមែនជាការសម្រេបសម្រួលតាមផ្លូវរាងកាយទេ តែជាលក្ខណៈមួយរបស់គំនិតយើង ។ ស្នេហាគឺជាតម្លៃគតិ ( une valeur spiritueile ) ។

ពិតមែនតែសេចក្តីស្នេហាជាចលនាមួយ ដែលនាំយើងទៅរកតម្លៃគតិ ទៅរកសោភ័ណស្នេហាអមតៈក៏ដោយ ក៏ទស្សនវិទូ

www.budinst.gov.kh www.elibraryofcambodia.org

នៅតែពុំអាចឈោងចាប់យកសម្រស់ស្នេហាអមតៈនេះបានដែរ ។ ទោះបីជាដូចនេះក៏ដោយ ក៏ទស្សនវិទូមិនអស់សង្ឃឹមបោះបង់ឧត្តមគតិស្វះស្វែងរកសោភ័ណស្នេហាអមតៈនេះឡើយ ព្រោះគេសង្ឃឹមថាថ្ងៃណាមួយ គេនឹងបានទទួលនូវស្នេហាដ៏ធំធេងពិតប្រាកដនោះជាមិនខាន ។

ដូច្នេះជីវិតទស្សនវិទូ ជាជីវិតមួយដែលរត់តាមសេចក្តីស្នេហាមិនចេះចប់មិនចេះហើយ ។

**La vie du philosophe est une course èternelle après l' amour. . .**


មានលក់ដុំ និងរាយ ទូរសៀវភៅអាន គ្រប់មុខវិជ្ជា
បារាំង, ចិន, ខ្មែរ, ថៃ, ជប៉ុន, អង់គ្លេស, ចំរៀង
KARAOKE រឿងដោយរូបភាព សៀវភៅធម៌ ។ល។
១.តូបលេខ 21+22+77 ជាន់ឡើងតឿ
ផ្សារអូរឫស្សី Tel : 012 982 980
: 012 862 018
២.តូបលេខ 68 ផ្សារថ្មី Tel : 012 863 315


www.budinst.gov.kh www.elibraryofcambodia.org

២០

# ភ្លើងកាមតម្រេក

មនុស្សយើងទាំងប្រុសទាំងស្រី ទោះក្មេងក្តីចាស់ក្តី តែកាលណាឮគេនិយាយ ឬឃើញគេឯងជិតខាង យកចិត្តទុកដាក់ចំពោះកាមគុណ ពោលអោយចំ គឺចំពោះបច្ចេកទេសរវាងស្ត្រី និងបុរស តែងតែធ្វើមុខក្រញូវ កាចសាហាវ មិនសប្បាយចិត្តហើយក៏តាំងប្រទេចផ្តាសាអ្នកដែលធ្វើអត្ថាធិប្បាយនោះភ្លាម ។

តែអ្នកដែលស្អប់ខ្ពើម ទាំងនោះភ្លេចខ្លួនឱ្យឈឹង ថាខ្លួនសព្វថ្ងៃ សុទ្ធតែរស់នៅក្រោមនឹម ក្រោមឱវាទនិងក្រោមបញ្ជារបស់សេចក្តីស្នេហា របស់កាមតណ្ហា ។ បានសេចក្តីថាសកម្មភាពទាំងប៉ុន្មាន ដែលយើងបានប្រព្រឹត្ត បានធ្វើបានអនុវត្តសុទ្ធតែជាសកម្មភាព ដែលមានប្រភពដើមនៅក្នុងកាមតម្រេក ( La libido ) ។ កំសួលកាមតម្រេកនេះដែលមានដើមកំណើតតាំងពីយើងកើតមកម្ល៉េះនោះ មាន

www.budinst.gov.kh www.elibraryofcambodia.org

ឥទ្ធិពលយ៉ាងខ្លាំងលើអាកប្បកិរិយា កាយវាចាចិត្តរបស់មនុស្ស គ្រប់ប្រាណ ។ គឺកាមតម្រេកនេះហើយដែលដឹកនាំ និងរៀបចំបុគ្គលិកលក្ខណៈនៃបុគ្គលគ្រប់ ៗ រូប ។

ដូច្នេះបញ្ហាស្នេហា បញ្ហាកាមតម្រេកនេះមិនមែនជាបញ្ហាដែលមិនសំខាន់នោះឡើយ ! គឺជាបញ្ហាមួយដែលមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងជីវិតរបស់សត្វគ្រប់ប្រភេទ ដូចជាស្រមោលដែលអន្ទោលទៅតាមប្រាណដូច្នោះ ។ ទាំងនេះបញ្ជាក់អោយយើងឃើញនិងយល់យ៉ាងច្បាស់ថា ជនដែលស្អប់និងដាក់កំហុសលើបញ្ហាស្នេហា លើកាមតម្រេក និងរឿងដទៃទៀតដោយឥតចេះខ្មាស់អៀន ។ ដូចយើងដឹងច្បាស់ហើយថា ជនទាំងនេះ មិនអាចជៀសផុតពីបញ្ហាស្នេហា បញ្ហាកាមតម្រេកនេះបានឡើយ ហើយប្រសិនបើឈ្លក់ងប់ក្បាលវិញ គឺមិនព្រមងើបអោយស្វាងឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯសិល្បៈគ្រប់វិស័យដែលមានលើដី ក្រោមមេឃយើងនេះ (បើតាមយើងសង្កេត) នឹងមានឈ្មោះល្បីល្បាញគ្រប់ទិសទី ហើយនឹងមានគេទទួលស្គាល់រាប់អានច្រើននោះ លុះត្រាតែសិល្បៈនោះ ចេះបញ្ចេញបញ្ចូលច្នៃរចនាបញ្ជាក់យ៉ាងច្បាស់លាស់នូវទិដ្ឋភាពពិត នៃសេចក្ដីស្នេហា ឬមួយក៏បង្ហាញអោយឃើញយ៉ាងជាក់ស្ដែង នូវទិដ្ឋភាពនៃការសេពសោយនិងការប្រព្រឹត្ត លុះដោយអំណាចកាមតម្រេក ។ ឯអក្សរសាស្ត្រដែលល្អវិញ ក៏គឺអក្សរសាស្ត្រដែលធ្លាប់បញ្ចេញនិងលាតត្រដាងអោយយើងឃើញសភាពពិតប្រាកដនៃកាមតម្រេកដែរ " អក្សរសាស្ត្រណាដែលខ្វះនូវរឿងដោះស្រាយបញ្ហាកាមតម្រេក ត្រូវតែចាត់ទុកថា មិនមែនជាអក្សរសាស្ត្រមែនទែនទេ ។ ហើយអក្សរសាស្ត្ររបៀបនេះ ក៏ត្រូវមតិអ្នកសិក្សាទាំងអស់ចាត់ទុកថាជាអក្សរសាស្ត្រមួយគ្មានន័យ គ្មានគេនិយមរាប់អាន ហើយមិនយូរមិនឆាប់ នឹងមុខជាត្រូវមតិអ្នកអានយកទៅគរទុកមួយកន្លែង

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងសមគួរ ។ តែប្រសិនបើមានលាយដោយរឿងរ៉ាវសព្វគ្រប់ដែលទាក់ទងនឹងបញ្ហាកាមតម្រេក នោះមតិមហាជននិងនាំគ្នាលើកយកមកជជែកពិភាក្សាមិនចេះចប់ មិនចេះហើយ ។

ឯក្នុងរង្វង់ឆាកនយោបាយវិញ អ្នកនយោបាយភាគច្រើនតែងតែធ្វើនយោបាយក្រោមការញ្ញាក់របស់កាមតម្រេកដែរ ។ គំរោងការណ៍នយោបាយរបស់គេនីមួយ ៗ សុទ្ធតែបានរៀបចំអនុវត្តធ្វើយ៉ាងដូចម្តេច អោយតែសេចក្តីស្រេកឃ្លានរបស់កាមតម្រេកនេះបានសំរេច បានឆ្អែតឆ្អន់បរិបូណ៌គ្រប់បែបយ៉ាង ទោះជាជាតិឬពិភពលោកទាំងមូលត្រូវរលំរលាយក៏ដោយ ។ ដូច្នេះសង្វាក់នយោបាយក្នុងពិភពលោកទាំងមូលសុទ្ធតែកម្រើក និងធ្វើការវិវត្តន៍ទៅតាមកម្លាំងធាតុរបស់កាមតម្រេក : C'est la sexue ité q' I règle le monde ។ ពិភពលោកអាចលូតលាស់ចំរើន ធ្វើដំណើរទៅកាន់វឌ្ឍនភាព ក៏ដោយសារកាមតម្រេក ហើយធ្វើដំណើរថយក្រោយចុះមករកភាពតឿនិយម និងហិន

www.budinst.gov.kh www.elibraryofcambodia.org

ហោចក៏ដោយសារកាមតម្រេកដែរ ។

ចំណែកសាសនាវិញ ទោះសាសនាណាក៏ដូចសាសនាណាដែរ បុគ្គលភាគច្រើនដែលលះបង់ជីវភាពរស់នៅធម្មតាជាគ្រហស្ថទៅបួសជាសង្ឃ ក៏មកតែពីបញ្ហាកាមតម្រេកនេះដែរ ។ មនុស្សយើងកាលនៅជាគ្រហស្ថ កាមតម្រេកចេះតែលុកលុយផុតកំដៅគ្រប់ពេលវេលាគ្មានស្រាកស្រាន្តឡើយ ហើយកាលណាដោះស្រាយមិនរួច ជនភាគខ្លះនោះក៏ដាច់ចិត្តផ្លាស់សំលៀកបំពាក់ចូលខ្លួនធ្វើជាសង្ឃ ដោយសង្ឃឹមថាបានជ្រះស្រឡះពីកាមតម្រេក ។ ពេលនេះព្រះសង្ឃអាចលះបង់កាមតម្រេកធុនធម្មតាសាមញ្ញនេះបាន តែមានកាមតម្រេកម្យ៉ាងទៀតដែលមានកម្រិតខ្ពស់ បានជម្រុញព្រះសង្ឃអោយស្វែងរកសេចក្ដីក្សេមក្សាន្តខាងផ្លូវចិត្ត និងស្វែងរកនិព្វានជាដើម ។

តើគេអាចមានវិធីណាមួយ ដែលអាចជម្រះផ្ដាច់បញ្ហាកាមតម្រេកនេះអោយដាច់ត្រឹមផុតពូជបានឬទេ ?

www.budinst.gov.kh www.elibraryofcambodia.org

បើតាមយោបល់យើង. យើងយល់ថាការបំបាត់ឱ្យផុតពូជបញ្ហាកាមតម្រេកនេះ ជារឿងមួយដែលហួសសមត្ថភាពនៃជនធម្មតា ។ គេដោះស្រាយបានខ្លះៗ ដែរ . . . តែបានម្តងមួយកាលប៉ុណ្ណោះ! រួចហើយកាលណា វាក៏កើតមានវិញ ដូចដើមដដែល ។

រួមសេចក្តីទៅ យើងឃើញថា កាមតម្រេកនេះមានឥទ្ធិពលមានអំណាចខ្លាំងក្លាណាស់ប្រៀបស្មើបាននឹងព្រះអទិទេព ។ កាមតម្រេកនេះហើយ ដែលជាអ្នកចាត់ចែង រៀបចំតុបតែងចលនាសង្វាក់ពិភពលោកទាំងមូល ។ បានសេចក្តីថា សត្វលោកគ្រប់រូបសុទ្ធសឹងជាតុក្កតារបស់កាមតម្រេកទាំងអស់ ។

ដូច្នេះ តុកកម្មលោកីយយើងនេះ រស់នៅក្នុងភ្លើងកាមតម្រេក !

www.budinst.gov.kh www.elibraryofcambodia.org

២៦

# បញ្ហាស្នេហា

នៅលើពិភពលោកយើងនេះ បញ្ហាស្នេហាជាបញ្ហាមួយធំបំផុតដែលគេត្រូវតែដោះស្រាយឱ្យបាន រហ័សរួសរាន់ទាន់ពេលវេលា ។ បើមិនដូច្នេះទេនោះ នឹងមានវិបត្តិមួយយ៉ាងធំកើតឡើងក្នុងសង្គមមនុស្សយើង ។

សេចក្តីស្នេហាមានន័យនិងអត្ថរសយ៉ាងធំ ខ្លាំងពូកែលើសលុបណាស់ វាមានមហិទ្ធិរិទ្ធិ អាចទាក់ទាញអោយមនុស្សឆ្កួតវង្វេងវង្វែងដឹងខុសត្រូវក៏មាន ឱ្យមនុស្សមានកម្លាំងកំហែងពូកែក៏មាន ។

ហេតុដូច្នេះហើយបានជាគេតែងតែ ឃើញអ្នកនិពន្ធខាងអក្សរសាស្ត្រចែកគ្នាជាក្រុមជាពួក ។ ក្រុមមួយ ស្រឡាញ់ខំអួតអាងនិងគោរពសេចក្តីស្នេហា ហើយមួយទៀតបែរជាប្រទេចផ្តាសារឿងស្នេហាទៅវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃរបស់អ្នកនិពន្ធ

១- La Dissertation littéraire

២- អាមុ៉កប្ញជនវិកលនៅម៉ាឡេស៊ី (ប្រែសម្រួលពីបរទេស)

៣- ម្ចាស់ប្តីដួងចិត្តអូន

៤- កម្រងទស្សនៈវិជ្ជា (ពីភាគទី ១ ដល់ភាគទី ៥)

៥- អំពីស្នេហា


បោះពុម្ពជាថ្មីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២

**ចំនួន ២.០០០ ក្បាលគត់**

បច្ចេកទេសកុំព្យូទ័រ : ឯល សេរីហ៊ួន

បោះពុម្ពដោយ : គីន ប៊ុនថន


www.budinst.gov.kh www.elibraryofcambodia.org

អ្នកដែលស្រឡាញ់គោរពនិងនិយមស្នេហាគឺសុទ្ធតែជាជន ដែលយល់ថាស្នេហាល្អស្នេហាជាប្រភពនៃសេចក្ដីសុខ ស្នេហាជាប្រភពនៃសុភមង្គល ដែលអាចឱ្យមនុស្សយើងមានកម្លាំងកំហែងសប្បាយក្នុងការរស់នៅក្នុងជីវិតនេះ ។ ចំពោះពួកគេនេះជីវិតមិនមែនឥតន័យនោះទេ ។ ដោយសេចក្ដីស្នេហាជាប់នៅជាមួយនោះ មនុស្សយើងលែងគិតឃើញពីការលំបាកអ្វីទៀតហើយ ។

សេចក្ដីស្នេហាជាឱសថទិព្វ អាចស្រោចស្រង់ជីវិតយើងឱ្យមានន័យ ។ គឺពេលនេះហើយដែលជីវិតយើង ពោរពេញទៅដោយសុភមង្គល ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏យើងមិនត្រូវភ្លេចដែរថា សេចក្ដីស្នេហានេះជាប្រភពនៃទុក្ខ ដែលធ្វើអោយមនុស្សយើងលុះដោយកាមគុណ ភ្លេចអស់ការពិត ការត្រឹមត្រូវយុត្តិធម៌និងការចម្រើនលូតលាស់ ។ ហេតុដូច្នេះហើយបានជាអ្នកនិពន្ធ

www.budinst.gov.kh www.elibraryofcambodia.org

ខាងផ្នែកអក្សរសាស្ត្រ ច្រើនតែចូលចិត្តរំកញ្ចែកលាតត្រដាងមុខអាក្រក់ នៃសេចក្តីស្នេហានេះ ។ ក្នុងខណៈនេះហើយដែលបុគ្គលយើងលុះដោយក្តីស្នេហាបែរទៅជាឥតវិញ្ញាណ គ្មានខួរក្បាលគ្មានសតិអារម្មណ៍ គ្មានវិចារណញ្ញាណត្រឹមត្រូវ ។ គេសុខចិត្តអោយសេចក្តីស្នេហាជិះជាន់សង្កត់សង្កិនគ្រប់ដណ្តប់ដឹកនាំប្រមុះគ្រប់ទិសទី គ្រប់ពេលវេលា ។

កាលណាលុះដោយសេចក្តីស្នេហា របៀបបែបអារត់អារាយហើយ បុគ្គលយើងម្នាក់ៗអាចធ្វើអ្វី ៗ បានទាំងអស់នោះក៏ត្រូវកំទេចពិភពលោកទាំងមូលក៏ដោយ អោយតែអាចផ្គាប់ចិត្តកំពូលដួងចិត្តនិងកំពូលជីវិតបាន ។ ក្នុងរឿងព្រេងនិទានមួយនៃប្រទេសក្រិចឈ្មោះថា " ចម្បាំងទៅត្រ័ " ( La gurre de Troie ) ព្រះអង្គម្ចាស់ "មេណេឡាស់" សុខចិត្តអោយពលរេហ៍ងាប់ដូចគេហាល រាប់មិនអស់ ដើម្បីខំដណ្តើមយកព្រះអង្គម្ចាស់ក្សត្រី "អេឡែន" ពីស្តេចនៃប្រទេសត្រ័វិញ ។

www.budinst.gov.kh www.elibraryofcambodia.org

ស្តេចខ្មែរព្រះនាមជ័យជេដ្ឋាទី២ វក់ដោយកាមគុណសុខចិត្តសម្លាប់ជាតិឯង សុខចិត្តលះបង់កេរ្តិ៍ដំណែលពីដូនតា. . . ។

ហើយប្រទេសកម្ពុជាយើងដែលរងទុក្ខ វេទនាសព្វថ្ងៃនេះ ដោយភ្លើងសង្គ្រាមគ្រប់ទិសទី តើមិនមែនដោយសារនយោបាយដែលអោយតណ្ហាអោយសេចក្តីស្នេហាដឹកច្រមុះទេឬអ្វី ?

ដូច្នេះយើងអាចយល់ឃើញថា មនុស្សយើងទោះបីខ្លាំងដូចម្តេចក៏ដោយក៏មិនអាចយកជ័យជំនះលើសេចក្តីស្នេហាបានដែរ ។ មនុស្សយើងអាចរស់អាចស្លាប់ដោយសេចក្តីស្នេហាបាន ហើយពិភពលោកក៏អាចរលាយរលត់ ឬ ចម្រើនរុងរឿងដោយវា ក៏បានដែរ ។ បើស្នេហាខ្លាំងម្ល៉ឹង១ ពូកែម្ល៉ឹង ១ ពុំគួរយើងបំបាត់វាចោលទេ គួរតែទុកវាយ៉ាងស្រួល ថ្នមវាអោយល្អគ្រាន់បានកែអផ្សុកក្នុងឆាកជីវិត ។ បើគ្មានស្នេហាទេ ជីវិតក៏គ្មានន័យ ឯផែនដីក៏ត្រូវរលត់ដែរ ពីព្រោះមនុស្សម្នាក់១ ដែលខំធ្វើការរកស៊ុចិញ្ចឹមជីវិតជិះជាន់គេ កាប់សម្លាប់គេឯងគឺគ្មានឃើញអ្វីក្រៅពីខំយកទៅបំរើត្រង់ចំណុចបញ្ហាស្នេហានេះឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## ៣០

ស្នេហាជារឿងមួយដែលមានអាយុជីវិតយូរយារណាស់មក ហើយ ។ ស្នេហាមិនមែនទើបតែចាប់បដិសន្ធិក្នុងបច្ចុប្បន្នកាល នេះទេ ។ អាយុវាចាស់ក៏រិលប្រហែលនិងដើមកំណើតនៃសត្វលោកទាំងអស់ដែរ ។ ហើយក្នុងបញ្ហាស្នេហានេះគេសង្កេតឃើញមានទ្រឹស្តីជាច្រើនដែលខំបញ្ជាក់អំពីដើមកំណើតរបស់វា ។

បើយើងយោលទៅតាមទ្រឹស្តីនៃព្រះពុទ្ធជាម្ចាស់ យើងឃើញថា ដើមកំណើតនៃសេចក្តីស្នេហារនេះគ្មានអ្វីក្រៅពីអវិជ្ជាឡើយ ។ អវិជ្ជានេះបណ្តាលឱ្យមានចិត្ត ចង់ចាប់កំណើតជាសត្វលោក ។ ហើយកាលណាតែចាប់កំណើតមានជីវិតរស់នៅជាសត្វលោកមួយរូបហើយ សត្វលោកទាំងនោះក៏ត្រូវតែហែលអណ្តែតត្រសែតត្រណោត់ត្រណែងក្នុងវាលវដ្តសង្សារ ។ ក្នុងវាលវដ្តសង្សារនេះ សត្វលោកជួបប្រទះជានិច្ចជានិរន្តរ៍ទ្វេរ

រស់ ចន្ទ្រាបុត្រ

www.budinst.gov.kh www.elibraryofcambodia.org

កាមតណ្ហានិងស្នេហាគ្រប់បែបធុន ។ ដូច្នេះវាសេវដ្ឋសង្សារនេះ ជាប្រភពនៃសេចក្តីស្នេហា ។

តែចំពោះគម្ពីរអេវ៉ាំងហ្គីល ( Evangile ) ខាងយេស៊ូវិញ យើងឃើញថាស្នេហាជារឿងដែលឲ្យមួយ ដែលកើតឡើងដោយឥតប្រុងប្រៀបជាមុនរវាងអាដាំ ( Adam ) និងអេវ ( Eve ) ។ តាមគម្ពីរនេះ ព្រះអាទិទេព កាលដើមដំបូងដៃ បានបង្កើតមនុស្សពីរនាក់អោយរស់នៅលើពិភពផែនដី គឺយើងនេះគឺអាដាំនិងអេវ ។ ព្រះអាទិទេពហាមប្រាប់អ្នកទាំងពីរនាក់នេះ មិនឱ្យឡើងបេះផ្លែប៉ោម បរិភោគដាច់ខាត ។

ដូច្នេះសត្វលោកទាំងពីរនេះ ចេះតែរស់នៅជាមួយគ្នាដោយឥតរឱសស្មានអ្វីបន្តិចឡើយ ។ គេរស់នៅជាមួយគ្នាក្នុងលក្ខណៈមិនយល់ការណ៍ ។ តែក្រោយមកសភាវៈអាក្រក់សាតង់ ( Satan ) បានមកបញ្ចូលចិត្តអ្នកទាំងពីរឱ្យឡើងបេះផ្លែប៉ោមមកបរិភោគ ។ ចាប់តាំងពីពេលនោះមក អាដង់ និង អេវ

www.budinst.gov.kh www.elibraryofcambodia.org

ក៏ចេះចាប់ចិត្តស្រឡាញ់ពេញគ្នាទៅវិញទៅមកភ្លាម ។ សេចក្តីស្នេហានេះហើយ ដែលបង្កបង្កើនឱ្យមានមនុស្សរស់នៅពាសពេញតែលើប្រថពី ។

តែបើតាមរឿងព្រេងនិទានរបស់ជនជាតិក្រិចវិញ គេថាមនុស្សយើងពីដើមមិនមែនមានក្បាលមួយ ដៃពីរ ជើងពីរ ដូចសព្វថ្ងៃនេះទេ តែកាលនោះ មនុស្សយើងមានក្បាលពីរ ដៃបួនជើងបួន ។ មនុស្សយើងមានមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់ ដែលជាហេតុការណ៍មួយ ទេវតាទាំងពួងច្រណែនឈ្នានីស ទៅទូលព្រះអាទិទេពស្ហ្គ៊ទែវ ( Jupiter ) ឱ្យដាក់ទោសមនុស្សយើងជាទម្ងន់ ។ ព្រះអាទិទេពក៏ចាប់មនុស្សយើងមកពុះជាពីរ ក៏មានក្បាលតែមួយ ដៃតែពីរនិង ជើងពីរដូចសព្វថ្ងៃនេះ ។

ដូច្នេះហើយបានជាក្នុងឆាកជីវិតរស់នៅនេះ ផ្នែកនីមួយៗគឺមនុស្សយើងដែលមានរូបរាងដូចសព្វថ្ងៃនេះ ចេះតែត្រេចវង្វេងដើរស្វះស្វែងរកមើលតើមួយផ្នែកទៀតនោះនៅឯណា ។

www.budinst.gov.kh www.elibraryofcambodia.org

អ្នកខ្លះដើររកក៏បានជួបដូចបំណងសុខស្រួលទៅ ។ អ្នកខ្លះទៀតទំរាំនឹងបានសម្រេចទៅតាមបំណងត្រូវបានទទួលទុក្ខវេទនាស្ទើរស្លាប់ស្ទើររស់ ។ អ្នកខ្លះទៀតមិនទាន់រកឃើញ ឬរកបានមួយផ្នែកទៀតផង ក៏ស្រាប់តែបាត់បង់ ជីវិតយ៉ាងអាណោចអធម្មបាត់ទៅ ។ នេះហើយគឺស្នេហា ។ សេចក្ដីស្នេហានេះបញ្ជាក់ត្រង់ដែលមួយផ្នែក ១ (La moitié ) ខំស្វះស្វែងរាវរកមួយផ្នែកទៀត ។

ដូច្នេះហើយ បានជាយើងសង្កេតឃើញថា គូស្នេហានីមួយៗ កាលណាបានជួបគ្នាម្ដង ៗ ហើយក៏តាំងឱបរិត ឱបហើយ ឱបទៀត គ្មានពេលជិនណាយ ឯពេលវេលាហាក់ដូចជាកន្លងទៅយ៉ាងឆាប់រហ័សណាស់... គូស្នេហាម្នាក់ៗសុទ្ធតែចង់រួមរិត ឱបគ្នាឱ្យតែមានក្បាលពីរដៃបួន នឹងជើងបួនដូចរូបរាងកាលដើម (forme primitive) រហូតដល់អវសានលោក ។

សេចក្ដីស្នេហានេះ មានកម្លាំងមហិមា ទាំងផ្នែកផ្លូវចិត្តនិងផ្លូវកាយ ។ សេចក្ដីស្នេហានេះមានលាយឡំទៅដោយ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីវេទនា ក្រលំបាក តោកយ៉ាក (la pauvreté )និងការសម្បូណ៌ហូរហៀរ មិនចេះខ្វះ (la richesse ) ។ អ្នកដែលមានសេចក្តីស្នេហា មិនបានសម្បូណ៌ហូរហៀរ ឬមានសុភមង្គលគ្រប់គ្រាន់ឡើយ ។ គេតែងតែជួបឧបសគ្គ និងទុក្ខវេទនាជាលំដាប់លំដោយ មិនចេះចប់មិនចេះហើយ ។

សភាពសំបូណ៌សប្បាយ លាយនឹងទុក្ខវេទនាដូច្នេះធ្វើឱ្យមនុស្សជឿស្លប់ និងវង្វេងងប់ក្នុងជីវិតដ៏សែនងងឹតនេះ ។ សេចក្តីសប្បាយជួយបន្ធូរបន្ថយទុក្ខអោយមនុស្សជឿថាមានសុភមង្គលល្អសប្បាយសម្បូណ៌ហូរហៀរចាក់ច្រាស់គ្រប់គ្រាន់មិនចេះខ្វះ ។

ដូច្នេះយើងឃើញថា ស្នេហាជាគ្រឿងភ្លេងមួយដែលបន្លឺឡើងសម្រាប់បន្ធូរនិងបន្ថយជីវិតងងឹតស្លុងស្លប់នេះ នៅក្នុងវាលវដ្តសង្សារ ។

ដូច្នេះស្នេហាជាឧបករណ៍មួយ ដែលមនុស្សយើងម្នាក់ៗមិនត្រូវមាក់អោយឬធ្វេសប្រហែសវាឡើយ ។ ស្នេហានេះហើយដែលដឹកនាំជីវិតមនុស្សលោកនិងជីវិតពិភពលោក ។

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី ២

www.budinst.gov.kh www.elibraryofcambodia.org

៣៦

# កាមតម្រេក

នៅក្នុងសង្គមមនុស្សយើង កាលណាគេលើកយកបញ្ហាកាមតម្រេកជជែកពីចារណា គេតែងតែជួបប្រទះនូវឧបសគ្គផ្សេងៗ នូវការមិនសប្បាយចិត្តពីសំណាក់អ្នកជិតខាង ។ ការដែល គេស្អប់មិនចូលចិត្តស្តាប់ ឬឮ ឬយល់ ពីបញ្ហាកាមតម្រេក មកពីគេយល់ថា វាជារឿងអមង្គលជារឿងឧបទ្រពចង្រៃ ។

ប៉ុន្តែបើយើងយោលទៅតាមការសិក្សាស្រាវជ្រាវតាមផ្នែកវិទ្យាសាស្ត្ររបស់មុខវិជ្ជា **ចិត្តវិភាគ** (la psychanalyse = psyké ចិត្ត + analyse វិភាគ ) វិញ យើងអាចយល់បានយ៉ាងច្បាស់ថា កាមតម្រេកនេះ ជាបញ្ហាមួយយ៉ាងធំបំផុតរបស់មនុស្សម្នាក់ ។

គឺជាបញ្ហាមួយដែលទាក់ទងយ៉ាងជិតស្និទ្ធ ជាមួយនឹងជីវិត

www.budinst.gov.kh www.elibraryofcambodia.org

១

# អារម្ភកថា

" អំពីស្នេហា" ជាសៀវភៅសាកល្បងមួយ (Essai) ដែលយើងបានខំធ្វើការស្រាវជ្រាវសិក្សា ដើម្បីរកធាតុពិតនៃសេចក្តីស្នេហា ។

ឯធាតុពិតនៃសេចក្តីស្នេហា ដែលយើងលើកយកមកអធិប្បាយវែកញែកដោះស្រាយនេះ គឺមាននៅក្នុងផ្នែកទស្សនវិជ្ជា ចិត្តសាស្ត្រ និងសង្គមសាស្ត្រ ហើយមានធ្វើការសិក្សាមួយទៀត ដែលស្តីអំពីលក្ខណៈ និងច្បាប់នៃសេចក្តីស្នេហាក្នុងសង្គមខ្មែរ ។

អត្ថបទខ្លះក្នុងការសាកល្បងនេះ បានត្រូវបោះពុម្ពផ្សាយរួចម្តងមកហើយ លើទំព័រសារពត៌មាន "សេដ្ឋកិច្ចខ្មែរ " និងក្នុង "កម្រងទស្សនវិជ្ជា " ភាគទី២ និងភាគទី ៣ ។

ឯការសាកល្បង " អំពីស្នេហា" ដែលយើងរៀបចំនៅពេលនេះ យើងបានកែសម្រួល បានចាត់ចែងទៅតាមជំពូកទៅតាមផ្នែក និងបន្ថែមការសិក្សាសាកល្បងជាច្រើនទៀត ដើម្បីបញ្ជាក់បង្ហាញអោយឃើញនូវការវិវត្តន៍របស់សេចក្តីស្នេហាតាំងតែពីក្នុងផ្នែកសង្គមទស្សនវិជ្ជា រហូតមកដល់ផ្នែកសង្គមមនុស្សធម្មតា ។

www.budinst.gov.kh www.elibraryofcambodia.org

ដែលត្រូវតែប្រព្រឹត្តទៅរហូតដល់ថ្ងៃអវសានរបស់យើង ។

ចិត្តវិភាគនេះ ទើបតែមានដើមកំណើត កើតឡើងនៅដើមសតវត្សទី ២០ ។ អ្នកប្រាជ្ញដែលបង្កើតចិត្តវិភាគនេះ ឱ្យរស់រានមានជីវិតនឹងគេក្នុងវង្សសៃវៀនវិទ្យាសាស្ត្រ ឈ្មោះ "ស៊ីមុនហ្វ្រឺដ " (Sigmund Freud ) ។ "ស៊ីមុនហ្វ្រឺដ " មានដើមកំណើតជាជាតិអូទ្រីស្ស ។ គាត់កើតនៅឆ្នាំ ១៨៥៦ ហើយស្លាប់ទៅវិញក្នុងឆ្នាំ ១៩៣៥ ។

ក្នុងចិត្តវិភាគនេះ "ហ្វ្រឺដ " បានសង្កត់ទ្រឹស្តីឱ្យស្ថិតជាពិសេសនៅលើបញ្ហាកាមតម្រេក ។ កាមតម្រេកជាធាតុភូត ដែលទាក់ទងជាមួយនឹងជីវិត កាមគុណ របស់យើងម្នាក់ៗ ។ ជីវិតកាមតម្រេកមិនមែនចាប់កំណើតកើតជានៅពេលដែលយុវជនពេញកម្លោះក្រមុំ (La puberté ) នោះទេ ។ តែជីវិតកាមតម្រេកនេះ ចាប់មានកំណើតតាំងពីមនុស្សយើងកើតមកម្ល៉េះ "ហ្វ្រឺដ " បានធ្វើការអធិប្បាយពន្យល់

www.budinst.gov.kh www.elibraryofcambodia.org

ពីលក្ខណៈកាមតម្រេកនេះ ដែលមានការវិវត្តន៍បន្តបន្ទាប់មក តាំងពីនៅវ័យកុមារ ។ (គោលគំនិតសំខាន់ស្ថិតនៅត្រង់ដែល គេដឹងថា នៅលើសារពាង្គកាយយើងមានកន្លែងខ្លះដែលអាចនាំ មកនូវក្តីសប្បាយ (le plaisir) ។ កន្លែងលើសារពាង្គកាយ ដែលអាចនាំមកនូវក្តីសប្បាយនេះ តែងតែផ្លាស់ប្តូរជាលំដាប់ លំដោយទៅតាមវ័យមនុស្សយើង ។

នៅក្នុងឆ្នាំទីមួយ មាត់របស់ក្មេង ជាប្រភពដែល ផ្តល់មកនូវការសប្បាយគ្រប់បែបយ៉ាង ដូចជាការបៅ ជញ្ជក់ ដោះម្តាយជាដើម ។ ដល់អាយុពីពីរឆ្នាំទៅបីឆ្នាំ កន្លែងកាម តម្រេកដែលផ្តល់មកនូវការសប្បាយនេះ ត្រូវមកស្ថិតលើត្រង់ កន្លែងគូថ (la zône anaje )ទៅវិញ ។ ពេលនេះក្មេង ចេះចូលចិត្តស្រឡាញ់ការស្អាតស្អំ ស្អប់ខ្ពើមការកខ្វក់ ។ ពីអាយុបីឆ្នាំទៅប្រាំឆ្នាំ គេឃើញថាកន្លែងកាមតម្រេកនេះមាន នៅកន្លែងលិង្គប្រភេទ (organe génile ) ។ ហើយពី

www.budinst.gov.kh www.elibraryofcambodia.org

អាយុប្រាំមួយឆ្នាំ រហូតដល់ជំទង់ បញ្ហាកាមតម្រេកដូចជាសម្ងំស្ងាត់បាត់សម្លេង ។ ប៉ុន្តែដល់ពេលវ័យកម្លោះក្រមុំ (**la puberté** ) កាលណា ភ្លើងកាមតម្រេកនេះ ក៏ចាប់ផ្តើមកញ្ជ្រោងឡើង ។ ពេលនេះ កាមតម្រេករបស់បុគ្គលម្នាក់ ៗ មានលក្ខណៈបាញ់ឆ្ពោះទៅរកបុគ្គល ដែលមានប្រភេទផ្ទុយពីគ្នា ។ កាមតម្រេកនេះមានសភាពពឹងផ្អែកទៅសរីរាងកាយនឹងទទួលឥទ្ធិពល នៃលក្ខណៈវប្បធម៌សង្គមជាតិ ។ ជាពិសេសទៅទៀត នៅក្នុងសង្គមយើង កាមតម្រេកនេះច្រើនតែស្ថិតនៅក្រោមឱវាទឥទ្ធិពល សាសនានឹងទំនៀមទម្លាប់សាសន៍ជាតិ ។

"ហ្វ្រើដ" យល់ថា កាមតម្រេកនេះជាមូលដ្ឋានសំខាន់បំផុតនៃសកម្មភាពគ្រប់បែបយ៉ាង របស់មនុស្សលោក ។ កាមតម្រេកនេះហើយដែលរៀបចំ និងអប់រំពត់នូវអាកប្បកិរិយា (**Le caractère** ) និងបុគ្គលិកលក្ខណៈ (**La personnalité**) របស់យើងម្នាក់ ៗ ។ កាលណាយើងបានសម្រេចកាមតម្រេក

www.budinst.gov.kh www.elibraryofcambodia.org

នោះការត្រូវការរបស់យើងក៏បានគ្រប់គ្រាន់ យើងក៏រីករាយសប្បាយចិត្តរីកថ្លើមប្រម៉ាត់ ។ តែប្រសិនបើកាមតម្រេកយើងមិនបានសម្រេចនូវសេចក្តីត្រូវការគ្រប់ប្រភេទនោះ គេនឹងកត់សំគាល់ឃើញមាន **សភាពខកចិត្ត** (La frustration) ។ កាលណាមានសភាពខកចិត្ត **សភាពកកផ្តុំ** (Le refoulement) ធ្វើអោយយើងមូម៉ៅក្តៅក្រហាយមិនសប្បាយចិត្ត ហើយចេះពៃទាស់ចិត្ត ។ សភាពកកផ្តុំនេះ កាលណាវាមានកំរិតខ្លាំងហើយវាអាចបណ្តាលអោយមាន **ជម្ងឺផ្លូវចិត្ត** (Les maladies psychopathologiques) ហើយជាពិសេស អោយមនុស្សទៅជាឆ្កួតលីលា ឱ្យមនុស្សមានការភ័យព្រួយខ្លាចតក្កមា (l'angoisse) មានក្តីអស់សង្ឃឹម និង ជ្រុលខ្លួនរហូតដល់ធ្វើអត្តឃាដកម្មក៏មាន (le suicide) ។

ក្នុងលក្ខណៈចុងក្រោយនេះហើយ ដែលមនុស្សយើងរស់នៅក្នុងពិភពមួយដែលពោរពេញទៅដោយក្តីអស់សង្ឃឹម ក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ពិភពមួយដែលខ្វះនូវឧណ្ហភាពនៃសុភមង្គល ។ ក្តីអស់សង្ឃឹមនេះហើយ ក្តីទុក្ខព្រួយសោយសោកសង្រេងនេះហើយ ដែលធ្វើឱ្យយើងមើលពិភពលោកឃើញខ្មៅងងឹតដុំជិត គ្មានរស្មីពន្លឺអ្វីគួរឱ្យត្រេកត្រអាលសោះឡើយ ។ ពេលនេះ យើងមានគំនិតមានទ្រឹស្តីមួយដែលហៅថា **និរាសាគតិនិយម** ( le pessimisme) ។ ឯជីវិតរបស់យើងវិញ ក៏គ្មានតម្លៃត្រង់ណាដែលគួរឱ្យយើងខំទ្រាំរស់នៅសោះឡើយ ( la vie ne vaut pas la peine d'être vécue ) ។

មួយផ្នែកវិញទៀត កាមតម្រេកអាចបញ្ជាក់ឱ្យយើងយល់យ៉ាងច្បាស់ថា សកម្មភាពគ្រប់បែបយ៉ាងរបស់ជីវិតមិនមែនសុទ្ធ តែពោរពេញទៅដោយសុភមង្គលនោះឡើយ ។ កាមតម្រេកអាចជំរុញឱ្យយើងមានកម្លាំង មានលទ្ធភាពក្នុងការបង្កបង្កើនអ្វីមួយជាប្រយោជន៍ដល់សង្គមមនុស្ស ដូចជាក្នុងមជ្ឈដ្ឋានវិទ្យា-សាស្ត្រ ទស្សនវិជ្ជាជាដើម ។ កាមតម្រេកអាចធ្វើឱ្យយើងមានកិត្តិយសល្បីល្បាញ ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះយើងមិនគួរដាក់ទោសដាក់កំហុស ទៅលើកាមតម្រេក ឬ ទៅលើអ្នកដែលលើកបញ្ហាស្នេហានេះមកនិយាយឡើយ ។ បើយើងនៅតែស្អប់ខ្ពើម ហើយដាក់ទោសកំហុសលើការសិក្សាពីកាមតម្រេក នោះក៏យើងពុំអាចទប់សកម្មភាពកាមតម្រេកនោះបានឡើយ ។ កាមតម្រេកនៅតែមានសកម្មភាពចាត់ចែង ទំព័រចិត្ត ទំព័រជីវិតយើងជានិច្ចជាកាល ។ កាមតម្រេកនៅតែមានឥទ្ធិពលជានិច្ចនិរន្តរ៍ លើអាកប្បកិរិយាចរិត ( le caracteré) និងបុគ្គលិកលក្ខណៈមនុស្សយើងជានិច្ច ។

កាមតម្រេក អាចជំរុញផ្តល់នូវភាពខ្ពង់ខ្ពស់ ( la grandeur) និងភាពទន់ខ្សោយ ( la faiblesse) ។

រស់ ចន្ត្រាបុត្រ

www.budinst.gov.kh www.elibraryofcambodia.org

## ៤៣

# លក្ខណៈស្នេហា

សេចក្តីស្នេហារវាងយុវបុរស និងស្ត្រី ជាសេចក្តីស្នេហាមួយដែលគេពុំព្រមផ្សាយចេញ ឱ្យនរណាម្នាក់ដឹងឮឡើយ ។ សូម្បីតែសាក្សី ក៏គេពុំត្រូវការឱ្យមានដែរ ។ ហើយសេចក្តីស្នេហានេះក៏គ្មានលក្ខន្តិកៈ កុងត្រា ( contrat ) អ្វីឱ្យពិតប្រាកដដែរ ។ ស្នេហាគឺជាភាពមួយដែលបង្រួបបង្រួមរូបកាយបុគ្គលពីរនាក់ដែលមានភេទផ្ទុយគ្នា ។

គោលបំណងធំបំផុតរបស់គូស្នេហានីមួយ ៗ មិនមែនថិតនៅត្រង់ការបង្កើតឱ្យមានគ្រួសារនោះទេ ! ... គូស្នេហានីមួយៗដែលខំស្រឡាញ់អោបគ្នាស្វិតនោះ គឺមកតែអំពី ចង់រំងាប់រំលាយឱ្យអស់នូវភ្លើងកាមតម្រេកដែលមានក្នុងរាងកាយ ។ ឯការដែលបណ្តាលឱ្យកើតជាកូនពូនជាចៅនេះ ជាលក្ខណៈចៃដន្យមួយឥតបានព្រាងទុកក្នុងកម្មវិធីដើមឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះយើងឃើញថា លក្ខណៈស្នេហាមានពីរយ៉ាង

១.ស្នេហាកាមតម្រេក ( Amour sexuel )

បុគ្គលម្នាក់ ដែលជាប់ស្រឡាញ់បុគ្គលមួយទៀត គឺមានគំនិតគិតធ្វើដូចម្តេច ឱ្យតែបានសម្រេចខាងកាមតម្រេក ។ គេចង់អោបរិតឱ្យអស់ចិត្ត ចង់ឱ្យរលាយអស់នូវកាមតម្រេកទាំងអម្បាលមាណ ។ គេចាត់ទុកថា គូរស្នេហារបស់គេនោះ ជាប្រភពនៃសេចក្តីសប្បាយ ជាប្រភពនៃស្ថានសួគ៌អណ្តែតអណ្តូង និងជាប្រភព នៃការសម្រាកកាយ ។ ពេលដែលយើងដកចិត្តជំពាក់ទៅលើបញ្ហានេះ នោះតណ្ហាអាចធ្វើអោយយើងមានសភាពការតឹងរឹងចង្អៀតចង្អល់ពិបាកដោះស្រាយ ។

កាលណារបស់អ្វីមួយ ( objet ) អាចផ្តល់មកនូវសេចក្តីសប្បាយ យើងតែងតែនឹកចង់បានរបស់នោះដើម្បីយកមកធ្វើឱ្យយើងសប្បាយទៀត ។

ដូច្នេះចំពោះមនុស្សម្នាក់ ដែលអាចធ្វើឱ្យយើងសប្បាយ

www.budinst.gov.kh www.elibraryofcambodia.org

រីករាយ យើងតែងតែមានចិត្តចង់ជួបមនុស្សនោះ ឱ្យបានជាញឹកញាប់ ។ សេចក្ដីត្រូវការមនុស្សម្នាក់ទៀត ដែលអាចផ្ដល់មកនូវសេចក្ដីសប្បាយរីករាយតាមផ្លូវកាយ ( Amour physique) នេះ កាលណាយូរ ៗ ទៅអាចប្រែក្លាយ ទៅជាស្នេហាតាមផ្លូវចិត្ត ( Amour actif ) ។ ពេលនេះហើយហើយគេសង្កេតឃើញសម្ផស្សរាងកាយបើកផ្លូវឱ្យមានសម្ផស្សតាមផ្លូវចិត្ត (ហើយផ្ទុយទៅវិញសភាពទន់ភ្លន់ក៏អាចបើកផ្លូវឱ្យមាន តម្រេកតាមផ្លូវកាយដែរ ជាពិសេសគឺការទន់ភ្លន់របស់ស្ត្រីភេទ ) ។

**២. ស្នេហាមនោសញ្ចេតនា ( Amour sentimental)**

ស្នេហាមនោសញ្ចេតនានេះ ជាជំហានទីពីររបស់សេចក្ដីស្នេហា ។ នេះបានសេចក្ដីថាគូស្នេហាម្នាក់ៗ បានឆ្លងផុតពីស្នេហាកាមតម្រេក ( Amour Sexuel) មកដល់ដំណាក់ការស្នេហាមនោសញ្ចេតនា ( Amour Sentimental ) ។

ក្នុងស្នេហាមនោសញ្ចេតនានេះ គេបានកត់សំគាល់ឃើញ

www.budinst.gov.kh www.elibraryofcambodia.org

ថាបុរសភេទដែលបានចាប់ចិត្តស្រឡាញ់ស្ត្រីណាម្នាក់ ក៏ដោយសារតែសម្ផស្សរាងកាយ និងដោយសារមនោសញ្ចេតនាជាជាងបំណងតាមផ្លូវកាមគុណ ។ តែចំពោះស្ត្រីភេទវិញសេចក្ដីស្នេហាមានមូលដ្ឋានពិតប្រាកដស្ថិតនៅលើកាមតម្រេក ។ ស្ត្រីភេទចាត់ទុកបុរសដែលនាងស្រឡាញ់ជារបស់មួយ ( objet our instrument ) ដែលអាចផ្ដល់ជូននាងវិញនូវសេចក្ដីរំភើបគ្រប់បែបយ៉ាងតាមផ្លូវកាមគុណ ។

ដូច្នេះ ឃើញថា មនោសញ្ចេតនាស្នេហា ( sontiment amoureux ) សុទ្ធតែមានប្រភេទដើមចេញ មកអំពីភ្លើងកាមតម្រេក ( la sexualité ) ទាំងអស់ ។

ភ្លើងកាមតម្រេកនេះហើយ ដែលដុតរោលកំដៅមនុស្សម្នាក់ៗឱ្យរំជើបរំជួល ឱ្យមនុស្សម្នាក់ៗ ធ្វើសកម្មភាពគ្រប់បែបយ៉ាងដើម្បីឱ្យស្នេហាកាមតម្រេកនេះបានសម្រេកដូចបំណង ។ តែដោយសារមនុស្សយើងជាសត្វលោកមួយ ដែលមានប្រាជ្ញាមាន

www.budinst.gov.kh www.elibraryofcambodia.org

២

ហេតុដែលយើងលើកយកបញ្ហាស្នេហា មកសាកល្បងដោះស្រាយវែកញែករកធាតុពិតនេះ មកពីយើងយល់និងជឿជាក់យ៉ាងច្បាស់ថា សេចក្ដីស្នេហានេះ មានភារកិច្ចធំណាស់ក្នុងការរៀបចំជម្រុញចិត្តមនុស្សម្នាក់ៗ និងកង់ប្រវត្តិសាស្ត្រ ។ ពោលអោយចំនៅបុគ្គលម្នាក់ៗធ្វើសកម្មភាពគ្រប់បែបយ៉ាង សុទ្ធតែលុះទៅដោយភ្លើងកាមតម្រេក ( La sexua'lté ) ដែលអ្នកប្រាជ្ញជាតិអូទ្រីស ឈ្មោះ "ស៊ីមុនហ្វ្រីដ" (Sigmond Freud ) ឱ្យឈ្មោះថា "លីប៊ីដូ" ( Libido ) ។

ដូច្នេះការសាកល្បងនេះ គ្រាន់តែជាវិភាគទានមួយយ៉ាងតូចបំផុតក្នុងការបង្ហាញជាទូទៅនូវធាតុពិតនៃសេចក្ដីស្នេហា និងមុខមាត់នៃសេចក្ដីស្នេហាក្នុងសង្គមខ្មែរតែប៉ុណ្ណោះ ។

ភ្នំពេញ, ថ្ងៃទី ២០ សីហា គ.ស ១៩៧០

រស់ ចន្ទ្រាបុត្រ

www.budinst.gov.kh www.elibraryofcambodia.org

វិចារណញ្ញាណ ( raison) ចេះរស់នៅក្នុងសង្គម ( être social ) ស្នេហា កាមតម្រេកក៏ក្រឡៃខ្លួនក្លាយទៅជាស្នេហាមនោសញ្ចេតនាទៅវិញ ។ ស្នេហាមនោសញ្ចេតនា នេះគឺជាស្បៃមួយដែលខំបំបិតបំបាំងសភាពពិតនៃសេចក្ដីស្នេហាកាមតម្រេកតែប៉ុណ្ណោះ ។ បើសំអាងទៅលើហេតុផលដូចមានខាងលើនេះ យើងឃើញថា ស្នេហាមនោសញ្ចេតនានេះគ្រាន់តែជាប្រដាប់តាក់តែងលំអសភាព គគ្រោតគគ្រើមនៃស្នេហាកាមតម្រេកតែប៉ុណ្ណោះ ។ ស្នេហាមនោសញ្ចេតនានេះធ្វើឱ្យស្នេហាកាមតម្រេកមានសភាពលន្លង់អន្លោចអណ្ដែតអណ្ដូងរសាត់ទៅ រសាត់មកមានសភាពផ្អែមត្រជាក់ ដែលជំរុញធ្វើឱ្យគូស្នេហាទាំងសង្ខាងរឹងរឹតតែមានអនុស្សាវរីយ៍គ្រប់បែបយ៉ាង ដែលអាចនាំឱ្យស្នេហាកាមតម្រេករឹតតែមានកម្លាំងខ្លាំងមាំឡើង ៗ ជាលំដាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ជនដែលមានស្នេហា

ជនម្នាក់ៗ កាលណាមានស្នេហាមកជិះជាន់ឈ្លីជាប់លើដួងចិត្តហើយ ចិត្តនេះចេះតែរេជានិច្ច ។ រីឯអារម្មណ៍មនោសញ្ចេតនាក៏ប្រែប្រួលប្រែផ្លាស់ប្ដូរជាលំដាប់លំដោយ ទៅតាមកាលៈទេសៈដែរ ។ ភាពនៃការផ្លាស់ប្ដូរចុះឡើងនៃចិត្តមនោសញ្ចេតនារបស់អ្នកដែលមានស្នេហាបញ្ជាក់ឱ្យយើងឃើញ និង យល់យ៉ាងច្បាស់ថា ស្នេហាមានអានុភាពខ្លាំងក្លាណាស់លើទំព័រជីវិតរបស់យើង ។

## ១. សភាពផ្លាស់ប្ដូរក្នុងការយល់ឃើញ

ជនដែលមានស្នេហា តែងតែមានការយល់ និង ការមើលឃើញភិភពលោក ទៅតាមមនោសញ្ចេតនារបស់ខ្លួន ។ ការចាប់អារម្មណ៍មើលឃើញរបស់ជនដែលមានស្នេហា បានធ្វើអោយវត្ថុជាទីស្រឡាញ់របស់គេមានសភាពផ្លាស់ប្ដូរ ។ ការដែលយើងអាចស្គាល់មនុស្សជុំវិញយើង( La connaissance d'autrui)

www.budinst.gov.kh www.elibraryofcambodia.org

គឺជាការស្គាល់មួយធម្មតា ដែលមានសភាពរហ័សរហួន ។ ខ្ញុំបាទស្គាល់មនុស្សជុំវិញខ្ញុំបាទ ដោយសារមិត្តទូទៅ និងដោយសារការរិះគិតពិចារណា ។ មនុស្សជុំវិញខ្ញុំ ( L'autrui ) ជាប្រភពមួយដែលពោរពេញទៅដោយគុណសម្បត្តិ ដែលអាចអោយខ្ញុំស្គាល់អ្នកនៅជុំវិញ ។ ការស្គាល់មនុស្សជុំវិញ ជាការស្គាល់នូវគោលគំនិត នូវទ្រឹស្តី និងនូវការត្រិះរិះគិតពិចារណា ។ ប៉ុន្តែចំពោះជនដែលមានចិត្តជក់ជាប់ជំពាក់ទៅដោយក្តីស្នេហាវិញកាលណាគេឃើញរបស់ស្នេហា គេអាចយល់ អាចស្គាល់របស់នោះទៅតាមរបៀបមួយដែលប្លែកពីការស្គាល់អ្នកនៅជុំវិញយើង។ សភាពស្ថិតនៅនៃមនុស្សជុំវិញ (L'existence d'autrui) ត្រូវប្រែក្លាយទៅជាសភាពស្ថិតនៅនៃគូស្នេហាទៅវិញ ។ ក្នុងពេលនេះការយល់ឃើញ ( La perception ) និងស្គាល់គូស្នេហ៍អាចធ្វើឱ្យរំជើបរំជួលឈឺចុកចាប់ក្នុងដួងចិត្ត ។ ជនស្នេហាអាចស្គាល់អាចយល់នូវទឹកចិត្តស្នេហា ។ គេអាចស្គាល់អាចយល់

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តគេបាន តែផ្ទុយទៅវិញ គេមិនអាចនិយាយប្រាប់និងពន្យល់អ្នកជិតខាងអោយយល់ចិត្តគំនិតនេះបានឡើយ ។ គេពុំអាចបញ្ជាក់ប្រាប់អ្នកផងថាតើគូស្នេហាគេ ខុសប្លែកពីអ្នកដទៃ ត្រង់កន្លែងណាឡើយ ។ ការលំបាកលំបិនក្នុងការរកយោបល់ដើម្បីបញ្ជាក់ប្រាប់អំពីក្តីស្នេហានេះ បង្ហាញយ៉ាងច្បាស់ទៅហើយថាគេមានសេចក្តីស្នេហាមែន ។ ជួនកាលគេអាចរកយោបល់ផ្សេងៗយកមកបញ្ជាក់អំពីស្នេហាគេដែរ តែយោបល់ទាំងនេះមិនបានគ្រប់គ្រាន់ឡើយ ព្រោះអីសេចក្តីស្នេហាមានសភាពធំវែងអន្លាយជាអតិបរិមា ដែលយើងពុំអាចអធិប្បាយរ៉ាយរ៉ាប់អោយបានច្បាស់លាស់ ។ម្យ៉ាងវិញទៀត កាលណាយើងចាប់ផ្តើម និយាយបញ្ចេញយោបល់ពីស្នេហានេះភ្លាម ពេលនោះគោលគំនិតពិសេស ៗ ខ្លះក៏វង្វេងវង្វាន់ភ្លេចបាត់អស់ ។ សេចក្តីស្នេហារបៀបនេះ មិនមែនដូចជាការស្រឡាញ់រាប់អាន (L'estime) និងការគោរព (Le respect) គ្នានោះឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ការស្រឡាញ់រាប់អាន ការគោរពគ្នានេះ គេប្រព្រឹត្តឡើងទៅតាមការដឹង ការយល់របស់យើងម្នាក់ ៗ ។ ដូច្នេះការស្រឡាញ់រាប់អាន និងការគោរពនេះ បញ្ជាក់យ៉ាងច្បាស់ស្រេចទៅហើយថាមានសភាពដាច់ពីគ្នា គឺគ្មានការជិតស្និទ្ធប្រកៀកប្រកើយឡើយ ។ សភាពដាច់ឆ្ងាយពីគ្នានេះ បញ្ជាក់អំពីការចែកនិងចាត់ឋានៈគ្នាក្នុងសង្គម ។ ការស្រឡាញ់រាប់អានឬការគោរពមនុស្សម្នាក់ៗ មិនមែនបានសេចក្តីថា យើងស្នេហាអ្នកនោះឡើយ **( Estimer ou respecter une personne n'est pas aimer )** ។

ក្នុងសេចក្តីស្នេហា គ្មានសភាពដាច់ពីគ្នាទេ ។ ពេលណាគេចាប់ផ្តើមស្នេហាហើយ ពេលនោះគេជឿជាក់ថាគេឈ្នះជានិច្ច គេសង្ឃឹមជានិច្ច ។ ហើយជាពិសេសទៅទៀតនោះស្នេហាស្ថិតនៅឯករាជ្យជានិច្ច ដោយគ្មានផ្លាស់ប្តូរទៅតាមការប្រួលប្រែរបស់ផ្នត់គំនិតយើងឡើយ ។ កាលណាខ្ញុំមានការចុកចាប់ឈឺផ្សាក្នុងដួងចិត្ត ការចុកចាប់ ការព្រួយបារម្ភ

BUDDHIST INSTITUTE LIBRARY

www.budinst.gov.kh www.elibraryofcambodia.org

ទាំងនេះ ពុំអាចមកផ្លាស់ប្តូរឬ ធ្វើអោយប្រួលប្រែសេចក្តីស្នេហាខ្ញុំចំពោះនារណាមួយឡើយ ។

សេចក្តីស្នេហា មានសភាពខុសប្លែកពីការស្វះស្វែងរកក្តីសប្បាយធម្មតា ( Le plaisir ) ។ ពីព្រោះយើងម្នាក់ៗ អាចស្រឡាញ់ប្រតិព័ទ្ធលើមនុស្សម្នាក់ ដែលចូលចិត្តតែធ្វើអោយយើងពិបាកចិត្ត អោយយើងខ្វល់ឥតល្ហែ ។ នាងណាដែលធ្វើឱ្យខ្ញុំប្រច័ណ្ឌអោយខ្ញុំច្រណែន អោយខ្ញុំចុកចាប់ក្នុងដួងហឫទ័យ នាងនោះហើយដែលធ្វើឱ្យខ្ញុំរឹតតែស្រឡាញ់ឡើង រឹតតែនឹកស្រមៃគ្រប់វិនាទីមិនចេះដាច់ ។ ផ្ទុយទៅវិញ បើនាងនោះស្លូតបូតមិនឆ្នាស់ឆ្នើមហើយស្រឡាញ់ថ្នាក់ថ្នមខ្ញុំ ខ្ញុំដូចជាមិនសូវសប្បាយចិត្តទេវិញ ... ចិត្តខ្ញុំហាក់ដូចជានៅខ្វះអ្វីមួយដ៏សំខាន់សំរាប់លួងលោមមនោសញ្ចេតនា ។

កាលណាខ្ញុំជាប់ចិត្តប្រតិព័ទ្ធលើនារីណាម្នាក់ហើយ ពេលនោះខ្ញុំខំធ្វើដូចម្តេចអោយតែនារីកំពូលដួងជីវិតរបស់ខ្ញុំ ពេញចិត្តនិង

www.budinst.gov.kh www.elibraryofcambodia.org

យកកែវភ្នែកទាំងគូក្រឡេកមើលមុខខ្ញុំ ។ ខ្ញុំពុំហ៊ានប្រឆាំងនិងយោបល់ និងការនឹកឃើញនិងយល់របស់នាងទេ ។ នាងចង់ធ្វើដូចម្តេចក៏ខ្ញុំជឿជាក់ ថាល្អប្រសើរជានិច្ច ទោះបីអំពើនោះមិនសមហេតុផលចាកសភាពពិតថ្លៃថ្នូរក៏ដោយ ។ ដូច្នេះសេចក្តីស្នេហានេះ បណ្តាលធ្វើអោយខ្ញុំខ្វាក់លែងមើលយល់ការពិតទៀតហើយ ។ សេចក្តីស្នេហាដែលចង់អប់រំគូរស្នេហាមិនមែននាំយើងអោយទៅរកសភាពរុងរឿងទេ ។ល។ សភាពស្នេហាដែលចង់ប្រដៅ គូស្នេហ៍តម្រូវអោយស្របទៅតាម ឧត្តមគតិរបស់ខ្លួន គឺជាលក្ខណៈមួយផ្ទុយស្រឡះពីសភាពស្នេហាពិត ១ ។ កាលណាបុគ្គលណាម្នាក់ចាប់ផ្តើមអប់រំគូស្នេហ៍របស់គេ អោយស្របទៅតាមគោលគំនិតរបស់គេ ពេលនោះ សេចក្តីស្នេហាក៏លែងមានជីវិតទៅទៀតដែរ ។ ស្នេហាគឺត្រូវតែស្រឡាញ់ស្នេហាទាំងអស់ខាងកំហុសតូចតាច ទាំងគុណសម្បត្តិ ( **Arirer c'est aimer avec ses defauts malgré tout** ) ។

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងដូចនេះ ស្នេហាធ្វើការវិវឌ្ឍន៍ឆ្ពោះទៅរកសភាពថ្កុំថ្កើង និងទៅរកសភាពអាក្រក់ហិនហោច ។

## ២.សភាពផ្លាស់ប្តូរនៃជនស្នេហា

កាលណាគេមើលឃើញគូស្នេហ៍គេ ឃើញថាល្អ ឃើញថាពេញចិត្តឥតខ្ចោះ ពេលនោះហើយសតិសម្បជញ្ញៈគេមានការស្រួបស្រួលរវើរវាយសប្បាយជាពន្លឹក ។ គេសប្បាយណាស់ដែលអាចស្រឡាញ់ប្រតិព័ទ្ធលើមនុស្សម្នាក់បាន ហើយដែលអាចធ្វើអោយគេចំណាំខ្លួនបាន ។ ដួងចិត្តគេពោរពេញ ទៅដោយមនោសញ្ចេតនាផ្សេង ៗ ។ ការរំភើបរំជើបរំជួលស្រើបស្រាលនេះធ្វើអោយយុវជន មានអត្តទត្តភាព ( L'égoïme ) ។ គេស្រមៃមើលឃើញជីវិតស្នេហានេះសប្បាយរីករាយមានសួរពិរោះរងំរណ្តំគួរឱ្យរំភើបក្រៃលែង ។ នេះស្នេហាជឿជាក់យ៉ាងប្បាស់ថា"តាំងពីដើមរហូតមកដល់ថ្ងៃនេះ មានតែក្នុងកាលៈទេសៈនេះទេ ដែលគេអាចក្រេប អាចស្គាល់រសជាតិស្នេហា

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងសប្បាយនឹងសម្បើមអស់ចិត្តចង់ ។ ជនស្នេហាភ្លេចគិតថាការដែលគេកំពុងតែសប្បាយរំភើបនេះ គឺគេកំពុងតែសប្បាយរំភើបលើគំនរគុណសម្បត្តិឡើយ ។ គេភ្លេចគិតថាក្នុងបញ្ហាស្នេហានេះ គឺមានបុគ្គលិកលក្ខណៈគេបានលាយឡំជាមួយខ្លះដែរ ។ ឯជីវិតរបស់គេបានប្រព្រឹត្តទៅតាមទិសដៅ ដែលសំរាប់តែបំរើគូស្នេហាប៉ុណ្ណោះ ។ សកម្មភាពទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា គេត្រូវការចង់បានគោលបំណងអ្វីមួយ ។

### ៣. សភាពផ្លាស់ប្តូរនៃសតិសម្បជញ្ញៈ

ក្នុងខណៈនេះ ធម្មជាតិនិងរបស់របរទាំងឡាយ ដែលស្ថិតនៅជុំវិញគូស្នេហ៍ ហាក់ដូចជាមានតម្លៃពន់ពេកប្រមាណនឹងកាត់ថ្លៃបាន ។ ធម្មជាតិ និងរបស់របរទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការផ្លាស់ប្តូសតិសម្បជញ្ញៈ របស់យើង ព្រោះធម្មជាតិ និងរបស់អស់ទាំងនោះជាសាក្សី នៃសេចក្តីស្នេហា ។ ជនស្នេហាបានយកមនោសញ្ចេតនារបស់ខ្លួនទៅផ្តិតជាប់នឹងការសប្បាយទាំង

www.budinst.gov.kh www.elibraryofcambodia.org

ឡាយដែលជារបស់គូស្នេហ៍ ឬមួយជារបស់ដែលនៅជិតខាងគេ ។ សម្លៀកបំពាក់, ផ្លូវថ្នល់, ផ្ទះសម្បែង . . . ។ ល។ និង ។ល។ អាចបណ្តាលចិត្តខ្ញុំរំភើបញាប់ញ័រសប្បាយផងភ័យផងហើយអោយខ្ញុំរស់ក្នុងការស្រមៃអណ្តែកអណ្តូងនឹកទៅដល់គូព្រលឹងខ្ញុំ ។ កន្លែងដែលនាងធ្លាប់អង្គុយ កន្លែងដែលនាងធ្លាប់ឈរ ថ្នល់ដែលនាងធ្លាប់ដើរ ម៉ាកឡានដែលនាងធ្លាប់ជិះ សំពត់អាវដែលនាងធ្លាប់ស្លៀកពាក់ មិត្តដែលនាងធ្លាប់និយាយទាំងអស់នេះ អាចទូងដួងចិត្តខ្ញុំអោយរំភើបញាប់ញ័រ រឭកដល់អនុស្សាវរីយ៍ទាំងអស់ដែលធ្លាប់ហែលនិងដែលធ្លាប់ស្គាល់... ធ្វើអោយខ្ញុំឃើញមុខនាង... ធ្វើអោយខ្ញុំចង់ត្រឡប់ថយក្រោយមករកទប់សង្វាក់ផែនដី ! ... តែអភ័ព្វអ្វីនេះជាការមួយហួសសមត្ថភាពខ្ញុំ...អ្វីទាំងអស់ដែលជារបស់នាងសុទ្ធតែមានតម្លៃចំពោះខ្ញុំទាំងអស់! គូស្នេហានីមួយៗ កាលណាបានទទួលចុតហ្មាយដួងចិត្តអ្វីមួយ ឬមួយក៏វត្ថុអនុស្សាវរីយ៍ពីជនដែលគេស្រឡាញ់ តែងតែរំភើបក្នុង

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី ១

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តជានិច្ច ។ កាលណាក្រឡេកមើលឃើញចុតហ្មាយ រឺ វត្ថុអនុស្សាវរីយ៍នោះភ្លាម គេក៏ឃើញវង់ភ័ក្ត្រផូរផង់ស្រស់បំព្រងរបស់ម្ចាស់ឥវ៉ាន់ភ្លាមដែរ ។ ជនស្នេហាតែងតែខំរក្សាថ្នាក់ថ្នមទុកដាក់មិនដែលធ្វេសនូវវត្ថុដ៏សែនមានតម្លៃទាំងនេះ ។ ហើយបើអាចយកទៅណាមកណាបាននោះ គេនឹងដាក់យកទៅជាមួយដែរ ព្រោះគេយល់និងជឿជាក់ថា បើមិនបានឃើញមុខ បើមិនបានឮសម្លេង ឃើញវត្ថុដ៏មានតម្លៃនេះ (ទោះបីជាថ្លៃថោកក៏ដោយ) ក៏ដូចជាបានឃើញវង់ភក្ត្រ័ ឬ ឮសំដីដ៏ផ្អែមពិរោះដែរ ។

ដូចអធិប្បាយមកនេះ ជនដែលមានស្នេហា សុទ្ធតែរស់នៅក្រោមឱវាទនៃសេចក្ដីស្នេហា ។ គេសង្ឃឹម និងរង់ចាំទទួលសម្រស់សើចញញឹមជានិច្ចពីគូស្នេហ៍របស់គេ ។ សកម្មភាពនិងកាយវិការតែបន្តិចបន្តួចតែប៉ុណ្ណោះ អាចចិញ្ចឹមជនស្នេហាអោយមានកម្លាំងពលំបាន ។ ឯជនស្នេហា មួយថ្ងៃៗ មានបញ្ហាស្មុគស្មាញរាប់មិនអស់ដែលចេះតែចោទសួរឡើងជាលំដាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

គេដណ្ដើងសួរតែខ្លួនឯង " តើគេហ៏មកឬទេ ? . . . " . . .

" តើគេហ៏ស្រឡាញ់ខ្ញុំឬទេ ? . . . " . . .

ដូច្នេះយើងសង្កេតឃើញថាមនុស្សម្នាក់ ៗ សុទ្ធសឹងតែជាឧបករណ៏របស់ស្នេហា ដែលបញ្ជាយើងរាល់រូប ដែលធ្វើអោយយើងមានកម្លាំងកំហែងក្នុងការរស់រានមានជីវិត និងដែលធ្វើអោយយើងអស់សង្ឃឹម ។

មានលក់ដុំ និងរាយ នូវសៀវភៅអាន គ្រប់មុខវិជ្ជា
បារាំង, ចិន, ខ្មែរ, ថៃ, ជប៉ុន, អង់គ្លេស, ចំរៀង
KARAOKE រឿងដោយរូបភាព សៀវភៅធំ ៗល ៗ
១.តូបលេខ 21+22+77 ខាងឡើងតើ
ផ្សារអូរឫស្សី Tel : 012 982 980
: 012 862 018
២.តូបលេខ 68 ផ្សារធំថ្មី Tel : 012 863 315

៥៩

# ទិដ្ឋភាពស្នេហា

អ្វីដែលមានរាងរៅ កើតផុសចេញមកស្ថិតនៅលើពិភពលោកយើងនេះ សុទ្ធតែមានរូបរាង មានលក្ខណៈ មានទិដ្ឋភាពផ្សេងៗ គួរអោយយើងចាប់អារម្មណ៍ ។ ឯសេចក្តីស្នេហាដែលបានចាប់បដិសន្ធិមានកំណើតដំណាលគ្នាជាមួយ នឹង ពិភពលោកដែរនោះ ក៏មានទិដ្ឋភាពគួរអោយចាប់អារម្មណ៍គយគន់ ចង់យល់ចង់ដឹង ចង់ឃើញដែរ ។

ទិដ្ឋភាពស្នេហានេះមានសភាពខ្លះដូចតទៅ :

-ទឹកចិត្តស្នេហាចំពោះគូសង្សារ

-សេចក្តីត្រូវការរបស់គូស្នេហា

-ការជ្រើសរើសគូស្រករ

-សភាពប្រឹងប្រែង

www.budinst.gov.kh www.elibraryofcambodia.org

## ១.ទឹកចិត្តស្នេហាចំពោះគូសង្សារ

ទឹកចិត្តស្នេហាដែលតែងតែសង្កេតឃើញមានរវាង គូស្នេហាពីររូបមានទ្រង់ទ្រាយនិងលក្ខណៈប្លែកៗ ពីគ្នាគួរឱ្យ រិះគិត ។

### ក.ទាសីស្នេហា (amour captif)

សង្សារណាម្នាក់ កាលណាមានទាសីស្នេហាក្នុងខ្លួន ហើយតែងតែប្រាថ្នាចង់អោយគូស្នេហារបស់គេនោះ ស្រឡាញ់គេអោយអស់ពីដួងចិត្ត ។ គេស្រឡាញ់បេតីចង់បានគូជីវិតគេសម្រាប់តែគេមួយគត់ក្នុងមួយជាតិនេះ ។ អ្នកណាក៏គ្មានសិទ្ធិអំណាចអ្វីមកដណ្តើមជិះជាន់យកគូស្នេហានេះបានឡើយ ។

ជនដែលមានទាសីស្នេហា រមែងច្រណែនប្រច័ណ្ឌជានិច្ច ហើយមានការស្រេកឃ្លាន ចង់បានវត្ថុស្នេហាមកសម្រាប់តែខ្លួនម្នាក់ឯងគត់ ។ ការស្រេកឃ្លានសេចក្តីស្នេហានេះ មិនចេះឆ្អែតឆ្អន់ ឬគ្រប់គ្រាន់ឡើយ ព្រោះអីគេតែងតែទឹកគិតឃើញជាប់អារម្មណ៍ជានិច្ច កាលណាវត្ថុជាទីស្នេហានេះចេះតែចង់

www.budinst.gov.kh www.elibraryofcambodia.org

គេចវេសអោយរួចពីកណ្តាប់ដៃខ្លួន ។ ការដែលចេះតែនឹកគិតឃើញថា ពុំអាចធ្វើជាម្ចាស់ស្នេហ៍បាននេះហើយ ដែលធ្វើឱ្យមនុស្សយើងមានការចុកចាប់ឈឺអស់ផ្លូវចិត្ត ផ្លូវកាយ ។ ដោយនាងកាកីជិតក្បត់ចិត្តទៅប្រតិព័ទ្ធក្រុងគ្រុឌ និងពុំអាចធ្វើជាម្ចាស់ចិត្ត លើនាងកាកីបាន ទើបព្រះបាទព្រហ្មទត្តត្រូវសោយសោកសង្រេងវិយោគឈឺចុកចាប់ក្រៃណានឹងបរិយាយ ។

**ខ.ស្នេហាលះបង់ ( amour oblatif )**

ក្នុងលក្ខខ័ណ្ឌនេះ គេសុខចិត្តលះបង់អ្វីទាំងអស់អោយតែគូជីវិតគេសប្បាយពេញចិត្ត ។ គេសុខចិត្តបូជាជីវិតគេ ឬ បូជាវត្ថុអ្វីដែលមានតម្លៃដើម្បីគូប្រចាំជីវិត ។ គេភ្លេចគិតអស់ហើយនូវជីវិតគេ នូវជីវភាពផ្ទាល់របស់គេ ។ គេសុខចិត្តលះបង់ឪពុកម្តាយ គ្រួសារ បងប្អូនដើម្បីសេចក្តីស្នេហាអមតៈ ។ ព្រះចន្ទគោរពសុខចិត្តលះបង់សម្រក់ឈាម ដើម្បីអោយគូស្នេហាបាត់ស្រេកទឹក ។ល។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងក្របខ័ណ្ឌនៃសេចក្តីស្នេហា នាងកេសរមាលា សុខចិត្ត លះបង់ការអៀនខ្មាស់ដែលជាលក្ខណៈរបស់ស្ត្រីភេទ ហើយហ៊ានក្បត់ចិត្តឪពុកនិងលះបង់នូវអ្វីៗ ទាំងអស់ ដើម្បីឱ្យតែបានជួបមុខ ចៅស្រទបចេក និង ដើម្បីឱ្យចៅស្រទបចេកសប្បាយចិត្តនិងស្រឡាញ់ខ្លួន ។ នាងសុខចិត្តលះបង់ទ្រព្យសម្បត្តិឪពុកម្តាយដែលជាសេដ្ឋី ដើម្បីទៅរួមរស់រហេមរហាមតោកយ៉ាកយ៉ាងកំសត់ជាទីបំផុត ជាមួយនឹងគូជីវិតរបស់នាង ។ល។ និង ។ល ។

ដូច្នេះ បញ្ហាធំគឺ ធ្វើដូចម្តេចឱ្យតែបានផ្គាប់ផ្គុនគូកំពូលដួងចិត្តរស្មី ជីវិតរបស់គេ ។

គ-ស្នេហារួមផ្គាប់ ( amour de communion)

ស្នេហាដោយរួមផ្គាប់នេះ ជាទិដ្ឋភាពមួយយ៉ាងខ្ពស់របស់សេចក្តីស្នេហា ។ កាលណាគេស្រឡាញ់គ្នាដោយរួមផ្គាប់ ហើយគឺគេសុខចិត្តសុខកាយរួមរស់ រួមស្លាប់ជាមួយគ្នាទោះបី

www.budinst.gov.kh www.elibraryofcambodia.org

ជាមានឧបសគ្គអ្វីមករារាំងក៏ដោយ ។ រូបកាយគេមានពីរមែន តែចិត្តគំនិតគេមានតែមួយគត់ ។ គេយល់ឃើញថារូបកាយគេទាំងពីរហាក់ដូចជាផ្សារជាប់គ្នាទាំងស្រុង ។ ឯចិត្តគំនិតគេក៏ដូចគ្នាបេះបិទទៀត ។ បើម្នាក់ស្លាប់ ម្នាក់ទៀតក៏ត្រូវតែស្លាប់ជាមួយដែរ ។ នាងទាវដែលបានដណឹងនិងឃើញជាក់ច្បាស់ថា ទុំត្រូវស្លាប់ដោយអំពើអយុត្តិធម៌របស់សង្គម ដែលចង់បំផ្លាញសេចក្តីស្នេហាបរិសុទ្ធរបស់នាង នាងក៏ដាច់ចិត្តបោកក្បាលសម្លាប់ខ្លួនតាមទុំប្តីបណ្តូលចិត្តរបស់នាងទៅដែរ ។ នាងយល់ថាសេចក្តីស្នេហានេះ គ្មានន័យអ្វីគួរអោយពិសាឡើយ បើគ្មានទុំជាអ្នកជួយរំលែក ។

### ២-សេចក្តីត្រូវការរបស់គូស្នេហា

កាលណាគេមានសេចក្តីស្នេហាហើយ ពិភពលោកទាំងមូលក៏ត្រូវតែប្រែប្រួលនៅតាមអារម្មណ៍ និងទៅតាមលក្ខណៈរបស់សេចក្តីស្នេហានេះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីស្នេហាគឺជាការត្រូវការ ស្រេកឃ្លានស្រឡាញ់បេតី និងការត្រូវការស្រេកឃ្លានអោយគេស្រឡាញ់បេតីតបមកវិញ។ សភាវៈកាមតម្រេក ( instinot sexuel ) មានសភាពវេរាចុះឡើងៗ មុននិងសម្រេចថាស្រឡាញ់អ្វីមួយ ។ សេចក្ដីស្នេហាបង្កបង្កើនអោយមានការឈឺចុកចាប់ដ៏ជ្រៅបេះដូង ដួងចិត្តក្រៀមក្រំ និងធ្វើឱ្យយើងមានសេចក្ដីរីករាយឃើញពិភពលោក ដែលស្អុះស្អាប់ងងឹតសូន្យឈឹង ប្រែទៅជាស្រស់ត្រកាលភ្លឺត្រចះគួរឱ្យចង់ចាំពុំចេះភ្លេច។ កាលណាមានឧបសគ្គក្នុងឆាកជីវិតស្នេហា ឧបសគ្គនេះជាអ្នកចិញ្ចឹមសេចក្ដីស្នេហា និងគុណធម៌ ( La vertu ) ។ ស្នេហាណាដែលគេដាក់ទោសដាក់កំហុស ដែលគេស្អប់ខ្ពើមស្នេហានោះហើយដែលរឹតតែមានកម្លាំងខ្លាំងឡើង ៗ ព្រោះតែយកបញ្ហានេះមកនឹកគិតមិនចេះចប់មិនចេះហើយ ។ ការគិតគូរនិយាយចុះឡើងនេះធ្វើឱ្យចិត្តគំនិតគេត្របាញ់ជាប់ទៅលើស្នេហាវិបត្តិ ដែលជាកត្តាមួយដុតរោលភ្លើងស្នេហា នេះឱ្យត្រូវតែឆេះឆួលខ្លាំងឡើង ៗ ។

www.budinst.gov.kh www.elibraryofcambodia.org

ជាពិសេសទៅទៀត សេចក្តីស្នេហានេះ ជារឿងដែលគេមិនត្រូវនិយាយរ៉ាយរ៉ាប់ប្រាប់នរណាក្រៅពីខ្លួនគេឡើយ ។ ស្នេហានេះជាប្រវត្តិមួយដែលទាក់ទង រវាងតែមនុស្សពីរនាក់ប៉ុណ្ណោះ ។

## ៣-ការជ្រើសរើសគូស្រករ

ការជ្រើសរើសរកគូស្រករមិនមែនងាយ ដូចដែលគេគិតឬស្រួលដូចដែលគេថានោះទេ ។ ការជ្រើសរើសរកគូស្រករនេះជួនកាលហាក់ដូចជាខុសផ្ទុយស្រឡះនឹងឧត្តមគតិហើយហាក់ដូចជាមានលក្ខណៈអាថ៌កំបាំង ។ មនុស្សយើងម្នាក់ ១ សុទ្ធតែជាប់ជំពាក់ក្នុង អនុស្សាវរីយ៍ដោយមិនដឹងខ្លួន ( souvenirs inconscients ) ។ អនុស្សាវរីយ៍មិនដឹងខ្លួននេះ ដឹកនាំខ្លួននឹងបញ្ហាចិត្តគំនិតរបស់យើង ដោយយើងគ្មានលទ្ធភាពនឹងដឹងយល់មុខដូចម្តេចផង ។

ដូច្នេះយើងអាចពោលបញ្ជាក់បានថា តណ្ហាកើតមាន

www.budinst.gov.kh www.elibraryofcambodia.org

ឡើងក្នុងខ្លួនយើងនិងដោយសារគ្មានយើង ( la passion naît en nous et sans nous ) ។ ជួនកាលគេ សង្កេតឃើញថា សេចក្ដីស្នេហាមានសូពូជមកទៀត ។ ជួនកាលទៅទៀតបុព្វហេតុតណ្ហានេះកើតមកពីសភាពរស់នៅក្នុងសង្គម ។ "បាល់ហ្សាក់" ( Balzac ) អ្នកនិពន្ធជាតិបារាំងដែលចូលចិត្តស្រឡាញ់តែស្រីដែលមានអាយុច្រើនជាងខ្លួន គឺមកពីកាលនៅវ័យកុមារគាត់ខ្វះការថ្នាក់ថ្នមអំពីម្ដាយ ។ នាងកាកីដែលផិតក្បត់ព្រះបាទព្រហ្មទត្ត មកពីស្ដេចនេះមានប្រពន្ធច្រើនមិនសូវបានរួមរក្សនែបនិត្យនិងនាង។ ហើយកក្ដាម្យ៉ាងទៀតគឺក្រុងគ្រុឌ ដំណែងខ្លួនក៏ស្រស់ហើយក្មេងទៀត ។

## ៤.សភាពប្រែប្រួល

កាលណាគេបានផ្ដោតចិត្តគំនិតទៅលើអ្នកណាម្នាក់ហើយ ចិត្តនោះក៏លោតកញ្ជ្រោលមិនឈប់មិនឈរ ហើយធ្វើឱ្យយើងចេះតែចង់គិត ចេះតែចង់ឃើញ ចេះតែចង់ពួសួរសុំដីដែលពិរោះ

www.budinst.gov.kh www.elibraryofcambodia.org

៤

# ស្នេហាជាអ្វី ?

បើយើងពោលឱ្យចំតែម្តងទៅ ស្នេហាមិនដឹងជាអ្វីទេ ! ការរកអត្ថន័យដាក់ឱ្យចំនឹងពាក្យ "ស្នេហា" នេះមិនមែនជាការងាយស្រួលដូចដែលគេនឹកស្មាននោះឡើយ ។

ឯការដែលគេចេះតែដាក់អត្ថន័យថាដូច្នេះ ថាដូច្នោះនោះ មិនមែនបានសេចក្តីថាអត្ថន័យទាំងនោះខុសឡើយ ។ ក៏ប៉ុន្តែអត្ថន័យទាំងនេះ ក៏មិនមែនបញ្ជាក់ថាត្រូវសុទ្ធសាធឥតខ្ចោះដែរនោះឡើយ ។

តាមការពិតទៅ ការរកអត្ថន័យ ដាក់ឱ្យចំឈ្មោះពាក្យ "ស្នេហា" នេះស្ថិតនៅក្នុងក្របខ័ណ្ឌមួយយ៉ាងពិបាកជាទីបំផុត ។ បានជាយើងពោលថាពិបាក ពីព្រោះយើងពុំអាចរកអត្ថន័យដាក់ដូចម្តេចឱ្យចំឥតខ្ចោះបានឡើយ ។ រីការពន្យល់ជម្រៅន័យនៃពាក្យ "ស្នេហា" នេះក៏ពិបាកដែរ ពីព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

គួរអោយលេប (ទុកជាមិនពិរោះក៏ដោយក៏នៅតែពិរោះដែរ) ។ ចិត្តគិតឃើញដែរ ថាត្រូវតែកុំនឹក ត្រូវតែកុំគិត តែវាគ្មានអំណាចឬប្រសិទ្ធិភាពត្រង់ណាដែលអាចបញ្ជាឱ្យ ឈប់នឹកបានឡើយ ។ សតិសម្បជញ្ញៈលែងធ្វើការ ហើយប្រែក្លាយទៅជាឥតប្រយោជន៍ ។

នៅក្នុងពេលនេះហើយ ដែលគេខំបញ្ចេញសកម្មភាពគ្រប់បែបយ៉ាងអោយបានប្លែក ។ ដើម្បីនឹងទាក់ទាញអារម្មណ៍របស់គូបណ្តូលចិត្ត ។ គេខំប្រឹងដូចម្តេចឱ្យតែគេយកភ្នែកមើល ទោះបីជាគេមើលដោយស្អប់ជិនណាយធុញទ្រាន់ដូចម្តេចក៏ដោយ ។ ខ្សែចក្ខុបន្ទិចរបស់គូស្នេហា អាចចិញ្ចឹមចិត្តស្នេហាអោយរស់ ឱ្យសប្បាយមានកម្លាំងខំតស៊ូទៅទៀត ដោយពុំខ្លាចក្តៅ ឬរងា ឬភ្លៀង មិនថាយប់ ឬ ថ្ងៃ មិនថាជិត ឬ ឆ្ងាយអ្វីឡើយ ។ ឯមុខវិញក៏ក្រាស់ឃ្មឹកដែរ ។

មនុស្សយើងអើយ... អីក៏អភ័ព្វម្ល៉េះ ! ! ! . . . ដឹងដែរឮ

www.budinst.gov.kh www.elibraryofcambodia.org

ដែរ យល់ដែរ ថាសេចក្ដីស្នេហា វាមិនព្រមស្ដាប់សម្លេងរបស់វិចារណញ្ញាណទេ ( la voix de la raison ) ថាស្នេហានេះធ្វើសកម្មភាពគ្រប់បែបយ៉ាងតាមតែវានឹកឃើញ ម្ដេចក៏នាំគ្នាឆ្ងាញ់នឹងស្នេហានេះម្ល៉េះ ? អ្នកមិនទាន់ស្គាល់ក៏ចង់ស្គាល់ ! អ្នកដែលស្គាល់ទៅហើយនោះក៏នៅតែចង់ស្គាល់ទៀត ! ការចង់ដឹង ចង់ស្គាល់រសជាតិស្នេហានេះគ្មានព្រំដែនអ្វីកំណត់ទុកសោះឡើយ!!

នេះបានចំជាធម្មជាតិមនុស្សមែន !! . . . បើគ្មានសេចក្ដីស្នេហាទេ នោះមនុស្សក៏លែងមានឈ្មោះជាមនុស្សដែរ !

រស់ ចន្ត្រាបុត្រ

www.budinst.gov.kh www.elibraryofcambodia.org

៦៩

# ការវិវត្តន៍នៃសេចក្តីស្នេហា

មនុស្សយើងម្នាក់ៗ កាលណាសេចក្តីស្នេហា បានមកចាប់ចិត្តសន្ធិក្នុងដួងចិត្តដួងអារម្មណ៍ហើយ ចិត្តនេះអារម្មណ៍នេះតែងតែវិវត្តន៍ទៅតាមលក្ខខ័ណ្ឌ និងរបៀបបែបផែន៧យ៉ាង ។ នេះបើយោលទៅតាមទ្រឹស្តីរបស់អ្នកនិពន្ធបារាំងឈ្មោះ "ស្តាន់ដាល់ ( Standhal ) ។

១-ការកោតសរសើរ ( admiration )

២-សេចក្តីសប្បាយរីករាយ

៣-សេចក្តីសង្ឃឹម

៤-ការចាប់បដិសន្ធិនៃសេចក្តីស្នេហា

៥-ភាពផ្តុំនៃសេចក្តីស្នេហាជាលើកដំបូង

៦-ការសង្ស័យ

៧-ភាពកកផ្តុំនៃសេចក្តីស្នេហាជាលើកទី២

www.budinst.gov.kh www.elibraryofcambodia.org

## ១-ពេលវេលាដែលត្រូវចំណាយដើម្បីស្នេហា

បើតាមការកត់សំគាល់របស់អ្នកដែលធ្លាប់មានការពិសោធន៍ និងធ្លាប់ធ្វើការសង្កេតក្នុងរឿងស្នេហានេះ ការវិវត្តន៍ពីភាពកោតសរសើរទៅភាពនៃការសប្បាយរីករាយ ត្រូវប្រើពេលវេលា មួយឆ្នាំយ៉ាងតិច ។ ពីភាពសប្បាយរីករាយទៅដល់លក្ខខ័ណ្ឌនៃក្តីសង្ឃឹម ត្រូវអស់រយៈពេលមួយខែ ។ ក្នុងកាលទេសៈនេះ បើសេចក្តីសង្ឃឹមគ្មានពន្លឺរស្មីនឹងចេញមកឱ្យបានភ្លឺត្រចះត្រចង់ទេនោះ សេចក្តីសប្បាយរីករាយទាំងប៉ុន្មាន ក៏ត្រូវតែរលត់រលាយទៅវិញដែរ ។ ឯទុក្ខសោកក៏កើតមានឡើង ។

ប៉ុន្តែបើក្តីសង្ឃឹមកើតមានហើយ ការវិវត្តន៍នៃសេចក្តីស្នេហាពីក្តីសង្ឃឹមមក ការចាប់បដិសន្ធិនៃសេចក្តីស្នេហា ក៏មានសភាពរហ័សរហួនដែរ ។ ឯភាពកកផ្ដុំស្នេហាខាងផ្លូវមនោសញ្ចេតនាក៏កើតឡើងជាដំបូងគួរឱ្យចាប់អារម្មណ៍ណាស់ដែរ ។ កាលណាសេចក្តីស្នេហាបានកកផ្ដុំហើយ ការប្រច័ណ្ឌ ការច្រណែន

www.budinst.gov.kh www.elibraryofcambodia.org

សង្ស័យក៏កើតមានឡើងដែរ ។ ឯថេរវេលានៃការវិវត្តន៍នោះក៏គ្មានភាពអ្វីគួរឱ្យកត់សំគាល់បានដែរ ។

២. ការកោតសរសើរ

មុននឹងសេចក្ដីស្នេហាបានចាប់បដិសន្ធិ គូស្នេហានីមួយៗត្រូវចេញពីលក្ខខ័ណ្ឌនៃការកោតសរសើរ ។ ដំបូងបង្អស់ម្នាក់ ៗ កាលណាជួបប្រទះមនុស្សម្នាក់ទៀត តែងតែធ្វើការវិនិច្ឆ័យផ្សេងៗ ។ ការវិនិច្ឆ័យនេះមានការមិនចូលចិត្តនិងមានការ កោតសរសើរ ។ ឯការកោតសរសើររវាងបុរសនិងស្ត្រីជាបច្ច័យ ដំបូងបំផុតនៃសេចក្ដីស្នេហា ។ ការដែលចេះតែកោតសរសើរ ហើយជួបប្រទះគ្នាជាញឹកញាប់នេះហើយ ដែលបង្កបង្កើនឱ្យមានក្ដីសប្បាយរីករាយ ។

៣. សេចក្ដីសប្បាយរីករាយ

ការដែលជួបគ្នាហើយចុះសម្រុងគ្នាទៀតនេះ ជាកត្តាមួយដែលធ្វើអោយមានការសប្បាយរីករាយ ។ មនុស្សយើងម្នាក់ ៗ

www.budinst.gov.kh www.elibraryofcambodia.org

កាលណារបស់អ្វីមួយឬបុគ្គលម្នាក់ទៀត អាចផ្តល់មកនូវក្តីសប្បាយរីករាយ ក៏តែងតែនិយមនិងបន់ស្រន់អោយបានជួបទៀតគ្រាន់នឹងបានសប្បាយរីករាយចិត្តបន្ថែមតទៅទៀត ។ ការចង់ជួបគ្នាជាញឹកញាប់នេះហើយ ដែលបណ្តុះបណ្តាលអោយក្តីសង្សឹមកើតមានរូបរាងឡើង ។

## ៤.សេចក្តីសង្ឃឹម

ក្នុងពេលដែលបុរសស្ត្រីមានក្តីសង្ឃឹម គេសង្កេតឃើញថាសាមុីជនមានលក្ខណៈផ្លាស់ប្តូខុសពីធម្មតា ។ គឺនៅពេលនេះហើយដែលស្ត្រីភេទត្រូវតែចុះចាញ់ ដើម្បីល្បងអោយបានស្គាល់នូវការសប្បាយទៅតាមផ្លូវការសប្បាយតាមផ្លូវរាងកាយ ។ ទោះបើស្ត្រីនោះមានលក្ខណៈតឹងរ៉ឹងហ្មត់ចត់យ៉ាងដូចម្តេចក៏ដោយក៏ភ្លែកឡើងក្រហមដែរ នៅពេលដែលមាន ក្តីសង្ឃឹម ។ ដល់កាមតណ្ហាឡើងខ្លាំងពេកទៅចំណង់ខាងការសប្បាយរីករាយក៏ខ្លាំងដែរ។ ឯសញ្ញាផ្សេងៗ ក៏បញ្ចេញ មកគួរអោយចាប់អារម្មណ៍ទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

## ៥-ការចាប់បដិសន្ធិនៃសេចក្តីស្នេហា

ក្នុងពេលដែលយើងចាប់ផ្តើមមានសេចក្តីសង្ឃឹម សេចក្តីស្នេហាក៏ចាប់ផ្តើមមានកំណើតដែរ ។ កាលណាសេចក្តីស្នេហាចាប់កំណើតហើយជនដែលមានសេចក្តីស្នេហា មានចិត្តចង់ជួបប្រទះស្គាល់នូវការសប្បាយរីករាយ ដែលគួរឱ្យគេអាចផ្តល់អោយបាន ។ ដូច្នេះស្នេហាបានសេចក្តីថាចង់ជួប ចង់ឃើញ ចង់ប៉ះពាល់ចង់អោយក្រេបរសជាតិអោយស្គាល់គ្រប់ៗ វិញ្ញាណ ហើយជាពិសេសស្នេហាត្រូវការ នៅជិតរបស់ដែលគេបេតី និងដែលបេតីគេតបមកវិញ ។

## ៦-គោពន្ធ៍នៃសេចក្តីស្នេហាជាលើកដំបូង

**( Première onstallisation)**

ពេលដែលសេចក្តីស្នេហាបានចាប់បដិសន្ធិកាលណាហើយ បុគ្គលម្នាក់តែងតែខំតុបតែងអួតអាងថា ស្ត្រីកំពូលស្នេហ៍របស់ខ្លួនល្អឥតខ្ចោះ ។ គេខំអួតអាងបញ្ជាក់ពីសុភមង្គលរបស់គេពុំចេះចប់ ។ ក្នុងលក្ខណៈនេះ គេយល់គេជឿជាក់ថា គូស្នេហា

www.budinst.gov.kh www.elibraryofcambodia.org

គេ មានលក្ខណៈល្អពិសេសពុំងាយរកជួបប្រទះបានឡើយ ។ គឺពិតជាបុប្ផាព្រះប្រទានដែលធ្លាក់ពីលើមេឃមកតែម្តង ។ ពេលនេះហើយដែលដួងចិត្តស្នេហារបស់គេកក្តុំ មើលទៅឃើញសុទ្ធតែល្អទាំងអស់ ទោះពីដើមមានលក្ខណៈដូចម្តេចក៏ដោយ ។ គឺប្រៀបទៅបាននឹងសុភាសិតខ្មែរដែលតែងតែពោលថា " ឃ្លានឆ្ងាញ់ស្រឡាញ់ល្អ " អញ្ចឹងដែរ ។ គឺនៅឱកាសនេះហើយដែលគេអាចរកឃើញវត្ថុដ៏មានតម្លៃ ដ៏ថ្លៃថ្នូរមួយទៀត ។

ឯការសប្បាយរីករាយ រឹតតែមានកំរិតខ្ពស់ថែមទៀត នៅពេលដែលរបស់ដែលគេស្នេហ៍ ចេះបញ្ចេញនូវសកម្មភាពដ៏ប្រពៃផ្សេងៗទៀត ។ ឧទាហរណ៍ បើមានជម្ងឺឈឺ ហើយបានគូស្នេហ៍យើងមកបបោសអង្អែលថែទាំរក្សារាល់ថ្ងៃ នោះយើងមុខជាសប្បាយរីករាយឥតឧបមា ។ ជាពិសេសទៅទៀតយើងលែងចង់ជាហើយ គឺចង់ឈឺជានិច្ច ដើម្បីអោយបានគេមកថ្នាក់ថ្នមអង្អែលទៀត ។ ក្នុងគ្រានេះហើយដែលតម្លៃរបស់គូ

www.budinst.gov.kh www.elibraryofcambodia.org

ស្នេហាយើងរឹតរឹតតែមានតម្លៃខ្ពស់ថែមទៀត ។

## ៧. ការសង្ស័យ

នៅពេលដែលសេចក្ដីស្នេហាបានកកផ្ដុំហើយ បុគ្គលដែលមានសេចក្ដីស្នេហា ក៏ប្រាថ្នាចង់បានវត្ថុជាទីស្រឡាញ់របស់គេនោះមកអោបក្រសោបមិនឱ្យអ្នកណាលួចកញ្ឆក់បានឡើយ ។ គេត្រូវ ការយករបស់នោះ មកធ្វើជាកម្មសិទ្ធិរបស់គេដោយផ្ដាច់មុខ ។ គេចង់អោយវត្ថុជាទីស្នេហារបស់គេនេះ ស្ថិតនៅស្មោះ ចំពោះរូបគេជានិច្ចជាកាល ។

ឯការប្រកាន់អាកប្បកិរិយា មិនសមហេតុសមផលខ្លះរបស់គូស្នេហាធ្វើអោយម្ចាស់ស្នេហ៍មានការសង្ស័យមិនទុកចិត្ត ។ ប៉ុន្តែបើតាមការសង្កេតរបស់យើងទៅឃើញថា មានតែស្ត្រីទេដែលច្រើនធ្វើអោយប្រុសសង្ស័យពុំសូវទុកចិត្ត ។ ឯលក្ខណៈដែលធ្វើអោយប្រុសៗសង្ស័យនេះ គឺបណ្ដាលមកគ្នាដែលជាស្ត្រីភេទកាលណាភ្ញាក់ស្មារតីដឹងខ្លួនកាលណាហើយ តែងតែមាននូវការ

www.budinst.gov.kh www.elibraryofcambodia.org

អៀនខ្មាស់ដែលជាទម្លាប់របស់ស្ត្រី ។ ការអៀនខ្មាស់នេះ ហើយដែលធ្វើអោយបុរសមានការសង្ស័យមិនទុកចិត្ត ។

## ៨-ភាពកក្តៅនៃសេចក្តីស្នេហាជាលើកទីពីរ

ការសង្ស័យមិនទុកចិត្តលើគូស្នេហានេះហើយ ដែលរឹងរិតតែជម្រុញអោយគូស្នេហាទាំងពីរ ស្រឡាញ់គ្នាថែមលើសពីមុនទៅទៀត ។ គឺពេលនេះហើយដែលមានភាពកក្តៅនៃសេចក្តីស្នេហាជាលើកទីពីរ ។ ពេលនេះគេហៅថា "ស្នេហារឹងប៉ឹង" ។ គេជឿជាក់ថា គូស្នេហាគេស្រឡាញ់ស្មោះត្រង់នឹងគេមែន ។ ជំនឿនេះបានកើតមានឡើងនៅពេលដែលមានការសង្ស័យមិនទុកចិត្ត ។ គេជឿជាក់ថាសង្សារគេស្រឡាញ់គេពិតប្រាកដមែន ។ ជួនកាលគេស៊ើងភ្លេចដកដង្ហើមទៅទៀតដោយក្តីស្នេហា ។ គេជឿជាក់ថា សង្សារគេមានគុណសម្បត្តិគ្រប់បែបផែន ហើយអាចផ្តល់មកនូវការសប្បាយរីករាយគ្រប់បែបផែន ។ ក្នុងគ្រានោះបុរសដែលជឿជាក់ទៅលើសេចក្តី

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យថា "ស្នេហា" មួយម៉ាត់នេះមានទំហំនិងតម្លៃធំធ្ងន់ឥតឧបមា ។

ដូច្នេះហើយបានជាចាប់តាំងពីពេលពិភពលោក យើងកើតមានរូបរាង មានអ្នកចេះគិតពិចារណាមកកាលណា បញ្ហា "ស្នេហា" នេះ នៅតែរកច្រកចេញដោះស្រាយពុំទាន់រួចរហូតមកដល់សព្វថ្ងៃនេះ ។ ឯទស្សនវិទូជាច្រើនក៏បានខំធ្វើការសិក្សាស្រាវជ្រាវអំពីបញ្ហា "ស្នេហា" នេះដែរ ។ ប៉ុន្តែចំបញ្ចប់នៃពាក្យ " ស្នេហា" នេះ ពុំទាន់ត្រូវបានទស្សនវិទូណាម្នាក់រកឃើញឡើយ ។

បើយើងជម្រុញការរិះគិតពិចារណានេះ ឱ្យបានវែងឆ្ងាយជ្រៅបន្តិចទៅ ចំពោះបញ្ហាពាក្យ "ស្នេហា" នេះយើងរឹងរឹតតែមានការឆ្ងល់ខ្លាំងឡើងៗទៅទៀត ។ បានជាយើងរឹងរឹតតែឆ្ងល់ឡើង ៗ មិនចេះចប់នេះ ពីព្រោះយើងពុំអាចដឹងថាតើប្រភពពិតប្រាកដនៃសេចក្ដី "ស្នេហា " នេះនៅកន្លែង

www.budinst.gov.kh www.elibraryofcambodia.org

## ៧៧

ស្នេហាតែងតែពោលនឹងគិតថា :

ក-សង្ស័យខ្ញុំមានគុណសម្បត្តិគ្រប់បែបយ៉ាង

ខ-សង្ស័យខ្ញុំគេស្រឡាញ់ខ្ញុំមែន

គ-តើធ្វើដូចម្តេចទៅអោយគេរឹងរិតតែស្រឡាញ់និងស្មោះ ត្រង់ចំពោះខ្ញុំទៀត ?

នេះហើយជាការវិវត្តន៍នៃសេចក្តីស្នេហា ។ ដែលមានលក្ខណៈជាធម្មតា ។ តែចំពោះស្នេហាកម្មក្រាស់វិញ គេឃើញតែការចុកចាប់គ្រប់បែបយ៉ាងតាមផ្លូវចិត្ត ។ សភាពកកផ្គុំនៃសេចក្តីស្នេហាក៏គ្មាន ឯសេចក្តីសង្ឃឹមទាំងប៉ុន្មានក៏ត្រូវរលត់រលាយអស់ !. . .

នេះហើយគឺរឿងពិតរបស់សេចក្តីស្នេហា !

រស់ ចន្ត្រាបុត្រ

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី៣

www.budinst.gov.kh www.elibraryofcambodia.org

៧៩

# ស្នេហានិងសង្គម

យោលទៅតាមទ្រឹស្តី ចិត្តវិភាគរបស់លោក " ស៊ីមុន ហ្វ្រើដ" យើងកត់សំគាល់ឃើញថា មនុស្សយើងម្នាក់ៗ មានសេចក្តីស្នេហានេះ តាំងតែពីចាប់មានកំណើតមកម្ល៉េះ ។ ពីកាមតម្រេកនេះហើយដែលធ្លាប់តាក់តែងរៀបចំជីវិត និងបុគ្គលិកលក្ខណៈរបស់យើង ។

ហើយជាបន្ថែមលើលក្ខណៈ កាមតម្រេក នៅមានបច្ច័យខ្លះទៀតដែលមានលទ្ធភាពក្នុង ការច្នៃទំព័រស្នេហាយើងនេះដែរ។ បច្ច័យក្រោមនេះ គឺសង្គម ( La société ) ។ ក្នុងសង្គមនិមួយៗ យើងសង្កេតឃើញមានលក្ខណៈពិសេស ។ ដូចជាទំនៀមទំលាប់សាសនា សេដ្ឋកិច្ច... ជាដើម ។ល។ ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើស្នេហា ។

ដូច្នេះបានសេចក្តីថា លក្ខណៈសង្គមជួយបន្ថែមបន្ថយជួយរចនាកុំអោយលក្ខណៈស្នេហានេះមានត្រឹមតែជាស្នេហាកាមតម្រេក

www.budinst.gov.kh www.elibraryofcambodia.org

តែឱ្យប្រែក្លាយទៅជាស្នេហាមួយ ដែលមានសម្ផស្សមានទឹកដមមានក្លិនក្រអូបឈ្ងុយឆ្ងាញ់. . . គួរអោយចង់បាន ចង់អោយត្រេកត្រអាល ។

## ១-ស្នេហានិងទំនៀមទំលាប់

នៅក្នុងសង្គមណាក៏ដូចសង្គមណាដែរ សេចក្តីស្នេហាតែងតែទទួលឥទ្ធិពលជាដាច់ខាតពីទំនៀមទំលាប់ របស់សង្គមដែលខ្លួនរស់នៅ ។ បើទំនៀមទំលាប់នេះមានបែបផែនទ្រង់ទ្រាយដូចម្តេច ស្នេហានោះក៏ប្រែប្រួលទៅតាមនោះដែរ ។

ឧទាហរណ៍ដូចជានៅខាងទ្វីបអឺរ៉ុប ជនជាតិសាសន៍គេដែលស្គាល់គ្នា ទោះស្រីក្តី-ប្រុសក្តី កាលណាជួបគ្នាម្តងៗគេតែងតែថើបគ្នា ដោយមិនគិតថាកន្លែងណាស្ងាត់ ឬមិនស្ងាត់ឡើយ ។ ការចាប់ដៃគ្នា ការថើបគ្នាទាំងនេះបានក្លាយទៅជាទំនៀមទំលាប់មួយ ដែលគ្មានអ្នកណាឃាំ គ្មានអ្នកណាសើចឡើយ ។ តែបើគេថើបគ្នាក្នុងរឿងស្នេហា នោះទំនៀមទំលាប់

www.budinst.gov.kh www.elibraryofcambodia.org

គេបានបង្ហាប់ថាអោយថើបបឺតជញ្ជក់មាត់គ្នា ។ ការនេះបានក្លាយ ទៅជាការធម្មតាមួយទៅហើយដែរ ។

តែចំពោះសង្គមខ្មែរយើងវិញ កាលពេលជួបគ្នាម្តង ៗ គេតែងតែនាំគ្នាសំពះទៅវិញទៅមក ។ សព្វថ្ងៃនេះ ដោយទទួលអារ្យធម៌បរទេស ខ្មែរយើងភាគច្រើន បាននិយមចាប់ដៃគ្នាខ្លះ ។ ហើយ ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ខ្មែរយើងមិនទាន់ដល់ថ្នាក់ថើបគ្នាដែរ ។ ការថើបគ្នានេះ គេបានបំរុងប្រគល់ទុកអោយតែគូបណ្តូលជីវិតតែមួយប៉ុណ្ណោះ ។ ដូចនេះក្នុងស្នេហាខ្មែរមានការបញ្ចោសអង្អែល ការថ្នាក់ថ្នម ការថើប ។ តែការថើបគ្នានេះ មិនទាន់មានជម្រៅដល់ទៅខាំជញ្ជក់បឺតមាត់គ្នាឡើយ... ព្រោះទំនៀមទំលាប់ពុំដែលមានបែបផែនចឹង ។ បើគេថើបគ្នាគេត្រូវតែយកច្រមុះគេទៅឈ្ងុលដូចក្របីហិតញ៉ើរញ៉ឹង ។ ហើយជាពិសេសទៅទៀតកិច្ចការទាំងនេះគេមិនអោយមានអ្នកទីបីពេលាសង្កេតការណ៍បានទេ ។ គេនាំគ្នាស៊ុំអោយស្ងាត់កំបាំងពីមុខមាត់អ្នកផងទាំងពួង ។

www.budinst.gov.kh www.elibraryofcambodia.org

ម្យ៉ាងវិញទៀត ទំនៀមទំលាប់ខ្មែរបង្គាប់ឱ្យគូស្នេហ៍គោរពកោតខ្លាចច្បាប់ប្រពៃណី ។ គេមិនត្រូវធ្វើឱ្យខុស ឬរំលោភលើប្រពៃណីឡើយ ។ គូស្នេហាណាដែលមិនប្រតិបត្តិតាមប្រពៃណីគូស្នេហានោះ ត្រូវគេចាត់ទុកជាជនក្បត់ប្រពៃណី ហើយត្រូវសង្គមគ្រួសារ ក្រុមញាតិសន្តានមិនទទួលស្គាល់រាប់អានទៀតផង ។

ក្រៅពីនេះទំនៀមទំលាប់ ជាភស្តុតាងមួយយ៉ាងធំក្នុងការបែងចែកវណ្ណៈស្នេហា ។ អ្នកធំគេស្រឡាញ់គេស្នេហាតែអ្នកធំដូចគ្នា គេមិនសូវរើតក្បាលរកអ្នកក្រទេ. . . បើបែរជាមករកអ្នកក្រវិញក្រែងតែអ្នកក្រនោះមានដំរេះវិជ្ជាខ្ពង់ខ្ពស់ ។ ជួនកាលទាល់តែរស់ផ្លូវជាមួយនិងអ្នកមានដូចគ្នា ទើបគេរេពមករកអ្នកក្រអោយទទួលផ្ទុបាក់ ។ ឯអ្នកក្រវិញឃើញវណ្ណៈ ខ្លួនអន់មិនសូវហ៊ានឈោងចាប់រកអ្នកវណ្ណៈខ្ពង់ខ្ពស់ឡើយ ព្រោះសមត្ថភាពខ្លួនទន់ខ្សោយមិនដល់ ។

នេះយើងគ្រាន់តែលើកយកទិដ្ឋភាពខ្លះៗ ប៉ុណ្ណោះ របស់

www.budinst.gov.kh www.elibraryofcambodia.org

ទំនៀមទំលាប់ដែលមានឥទ្ធិពលទៅលើស្នេហាមករាប់រៀប ។

## ២. ស្នេហានិងសាសនា

មិនត្រឹមតែទទួលឥទ្ធិពលទំនៀមទំលាប់ប៉ុណ្ណោះទេ សេចក្តីស្នេហា នៅទទួលឥទ្ធិពលរបស់សាសនាទៀត ។

សាសនាអាចខាំងនិងអាចបណ្តុះបណ្តាល អោយស្នេហារឹតតែមាំខ្លាំងឡើង ។

នៅខាងទ្វីបអឺរ៉ុបកាលណាគូស្នេហាពីរនាក់គោរពសាសនាខុសគ្នា គេពុំអាចរៀបការយកគ្នាជាប្តីប្រពន្ធបានឡើយ ។ បើគេចង់យកគ្នាជាប្តីប្រពន្ធគេត្រូវតែប្រកាន់យកសាសនាតែមួយ ដូចគ្នាជាមុនសិន ។

ចំណែកព្រះពុទ្ធសាសនាខ្មែរយើងវិញ អាចចងភ្ជាប់គូស្នេហាប្តីប្រពន្ធទាំងពីរ អោយចេះទ្រាំរស់នៅជាមួយគ្នា និងឱ្យរឹតតែស្រឡាញ់គ្នាថែមទៅទៀត ។ ទ្រឹស្តីព្រះពុទ្ធជាម្ចាស់បានចែងយ៉ាងច្បាស់ថា បើយើងបានជួបគ្នានេះ មកពីយើងជាគូព្រេងពីអតីតមកពីយើងធ្លាប់ជួបគ្នាពីជាតិមុនរួចមកហើយ ។ ឯការរស់នៅ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងវាលវដ្ដសង្សារនេះ គេតែងតែជួបនូវបាបកម្មពៀរវេរាជានិច្ច ។ ដូច្នេះបើមានការខុសទាស់ឆ្នាំឆ្លងបន្ទិចបន្តួចនៅក្នុងគ្រួសារ ធ្វើម្ដេចទ្រាំទៅព្រោះនេះជាកម្មពីជាតិមុន . . . ហើយព្រោះជាគូព្រេងពីនាយ ! . . . ព្រះពុទ្ធសាសនា ចេះតម្រែតម្រង់ស្នេហាមនុស្សម្នាក់ ។ អោយនៅនឹងហើយត្រង់ជានិច្ចដោយប្រដៅមនុស្សម្នាក់ៗ អោយស្រឡាញ់និងចេះយកតែប្រពន្ធមួយ កុំអោយលួចប្រពន្ធកូនគេ និងអោយចេះផ្ដាច់នូវក្ដីលោភលន់និង កាមកិលេសទាំងប៉ុន្មាន ។

## ៣. ស្នេហានិងសេដ្ឋកិច្ច

ក្រៅពីទំនៀមទំលាប់និងសាសនា ស្នេហានៅត្រូវទទួលឥទ្ធិពលជាពិសេសពីបញ្ហាសេដ្ឋកិច្ចទៀត ។ បញ្ហាសេដ្ឋកិច្ចនេះបានបំពត់ផ្ចត់គំនិតបុគ្គលម្នាក់ៗ ដោយមិនដឹងខ្លួន ។

កាលណាផ្ចត់គំនិតបុគ្គលម្នាក់ៗ យោលទៅតាមទ្រឹស្ដីសេដ្ឋកិច្ចនិយមហើយ ពេលនោះក្នុងបញ្ហាស្នេហា គេតែងតែយកបញ្ហានេះមកគិតពិចារណា ដោះស្រាយជានិច្ច ។ គេតែង

www.budinst.gov.kh www.elibraryofcambodia.org

តែគិតថាតើស្នេហានេះអាចនាំមកនូវការចំណេញប៉ុន្មាន ?. . . ការចំណាយប៉ុន្មាន ? . . .

ដូច្នេះមុននឹងស្រឡាញ់លើរូបអ្នកណាម្នាក់ ឬមុននឹងទុកដាក់កូនចៅ គេតែងសម្លឹង "មើលកាក" ជានិច្ច ។ គេខំគិតខំវាស់ស្ទង់ស្ទាបប្រមើលថាតើគេអាចប្រមូលប្រយោជន៍បានប៉ុន្មានសម្រាប់ធ្វើអោយជីវិតគេ អនាគតគេ រីងរឹតតែភ្លឺស្វាងរុងរឿងតទៅទៀត ? . . .

បញ្ហាសេដ្ឋកិច្ចនេះ គឺជាបញ្ហាគិតប្រយោជន៍ផ្ទាល់ខ្លួន ។ ការគិតប្រយោជន៍ផ្ទាល់ខ្លួននេះ អាចធ្វើឱ្យបុគ្គលម្នាក់ៗ ប្រឆាំងនឹងទំនៀមទំលាប់ និងសាសនា. . . ក៏មាន ។

ហើយក្នុងសម័យឥឡូវនេះក្នុងកាលៈទេសៈដែលវិទ្យាសាស្ត្រចេះតែចំរើនលូតលាស់ បញ្ហាសេដ្ឋកិច្ចចេះតែចោទឡើងជាបញ្ហាមួយក្នុងជីវភាពមនុស្សម្នាក់ៗដែរ ។ ឯជីវភាពស្នេហាក៏ត្រូវទទួលនូវអំណាចគ្របសង្កត់របស់វិទ្យាសាស្ត្រនេះ ។ មនុស្សប្រុសស្រីដែលស្រឡាញ់គ្នាតែងតែនឹកគិតពីបញ្ហាសម្ភារៈ ដែលជា

www.budinst.gov.kh www.elibraryofcambodia.org

លទ្ធផលរបស់វិទ្យាសាស្ត្រ ។ គេស្នេហាគ្នាផង គេស្រមៃផង បានគ្រឿងសម្ភារៈប្រើប្រាស់ឱ្យបានច្រើនផង . . . ។

ដូចដែលយើងបានអធិប្បាយដោយយ៉ាងៗ មកនេះ យើងអាចសំគាល់ឃើញថា សេចក្ដីស្នេហាមានគោលបំណងត្រឹមត្រូវអោយបានត្រេកត្រអាលសំរើបសំរួលតាមផ្លូវកាយមែន តែហួសពីនេះទៅទៀត ការត្រេកត្រអាល នេះត្រូវលាក់ខ្លួនពួកអាត្មានៅក្រោយទិដ្ឋភាពផ្សេងៗ របស់សង្គមជាតិ ។ ដូច្នេះសំបកក្រៅរបស់ស្នេហា ដែលត្រូវការសប្បាយដោយផ្លូវបំពេញកាមតណ្ហា គឺជាលក្ខណៈពិសេសរបស់សង្គម ។

ដូច្នេះបន្ទាប់ពីការសប្បាយ ដោយផ្លូវកាមគុណ កាមតម្រេក មនុស្សត្រូវការរស់នៅក្នុងសង្គម ។ ដើម្បីចិញ្ចឹមជីវិត ដើម្បីរស់នៅក្នុងសង្គម មនុស្សយើងត្រូវតែសម្រេចសម្រួលកាយវាចាចិត្តរបស់ខ្លួន អោយស្របតាមការត្រូវការរបស់សង្គម ។ ឯសេចក្ដី ស្នេហាក៏ធ្វើដំណើរទៅតាមជីវភាពនេះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

ណាមួយឡើយ ។ យើងដែលជាមនុស្សចេះតែពោលពាក្យ "ស្នេហា" ៗ តែយើងពុំអាចស្គាល់ថា "ស្នេហា" នេះយ៉ាងដូចម្ដេចទេ ។ យើងពុំអាចចាប់វាបានឡើយ ។ ឯប្រភពរបស់វាសោតក៏យើងពុំអាចដឹងថាស្ថិតនៅទីកន្លែងណាដែរ ។

យើងចេះតែទន្ទេញពាក្យ "ស្នេហា" ជាប់មាត់ជានិច្ច ហើយម្នាក់ៗចេះតែខំប្រឹងរកយល់និងពន្យល់ថាស្នេហាមានន័យដូច្នេះ មានន័យដូច្នោះ អ្នកនេះបង្កើត អ្នកនោះបង្កើត ជាហូរហែមិនចេះចប់ ។ ឯទីបញ្ចប់ស្នេហានៅតែស្នេហាដដែល ។

បើយើងកុំយកបញ្ហាព្រះអាទិទេពមកដោះស្រាយ កុំយកបញ្ហាកម្មផលអវិជ្ជាមកឆ្លើយឆ្លង ហើយយើងយកតែបញ្ហាដែលយើងឃើញផ្ទាល់នឹងភ្នែកក្នុងរយៈពេល ដែលយើងកំពុងតែមានជីវិត យើងរឹតតែមានការឆ្ងល់ខ្លាំងទៀត ។ តាមការសង្កេតផ្ទាល់នឹងភ្នែកធម្មតា យើងឃើញថា ទារកដែលទើបនឹងកើតភ្លាមមកមិនចេះ មិនយល់ មិនស្គាល់អ្វីទៅដែល ហៅថាស្នេហា

www.budinst.gov.kh www.elibraryofcambodia.org

៨៧

# ទម្រង់ស្នេហាខ្មែរ

( Les formes de l'amour Khmer)

នៅក្នុងសង្គមខ្មែរយើងពាក្យថាស្រឡាញ់ ពាក្យថាស្នេហាមិនសូវបានគេយកមកប្រើឱ្យបានពេញមាត់ពេញកទេ ។ ព្រោះគេចាត់ទុកថាស្នេហានេះ និងកើតឡើងកាលណាគេបានរៀបអាពាហ៍ពិពាហ៍រួចហើយ ។ ម្យ៉ាងវិញទៀត គេយល់ថាស្នេហានេះមានន័យថាលបលួចស្រឡាញ់គ្នាមុន ។ ហើយការស្រលាញ់គ្នាមុននេះ ជាព្រឹត្តិការណ៍មួយដែលសង្គមខ្មែរជាទូទៅទាំងប្រទេស ទាំងស្រីទាំងប្រុស ទាំងក្មេង ទាំងចាស់ នាំគ្នាដាក់ទោសដាក់កំហុសមិនសូវរាប់អានឡើយ ។ ការលបលួចស្រឡាញ់គ្នាមុន ទោះបីត្រឹមតែចិត្តនិងចិត្តក៏ដោយ (មិនទាន់ធ្លាយដល់រូបកាយ) ក៏គេនាំគ្នាស្អប់ខ្ពើមឆ្អើមដែរ ព្រោះអំពើនេះជាអំពើក្បត់នឹងប្រពៃណីខ្មែរ ។

## ១. ប្រពៃណីខ្មែរ

ដូច្នេះក្នុងសង្គមខ្មែរ គេចាត់ទុកថាប្រពៃណីទំនៀមទំលាប់

www.budinst.gov.kh www.elibraryofcambodia.org

នេះជាធំ ។ ជនណាដែលសុខចិត្តអោយប្រពៃណីដឹកច្រមុះឱ្យដើរ តាមជននោះនិងត្រូវគេលើកស្ទួយសរសើរមិនដាច់ពីមាត់ ។ ក្នុងសង្គមខ្មែរយើង បុគ្គលម្នាក់ៗមិនមែនជាអ្នកសម្រេច ឬជាអ្នកសាងវាសនាអនាគតខ្លួនដោយខ្លួនឯងទេ ។ គឺមាតាបីតាឯណោះទេ ដែលជាអ្នកសម្រេចជោគវាសនារបស់កូន ។ គាត់ចង្អុលផ្លូវ ចាប់រុញក្បាលកូនអោយដើរតាម "គន្លងធម៌" របស់គាត់ ។ កូនប្រុសកូនស្រី គ្មានអំណាចអ្វីនឹងដឹងឮ និងយល់ និងដោះស្រាយបញ្ហាស្នេហាអោយស្របទៅតាមឧត្តមគតិរបស់ខ្លួនឡើយ ។ កូនប្រុសកូនស្រី ត្រូវតែនៅឱ្យស្ងៀមដូចជាតុក្កតា ចាំតែទទួលបញ្ជា ហើយអនុវត្តតាមគោលដៅជាការស្រេច ។ អ្នកដែលចាត់ចែង រត់រកស្រាវជ្រាវរើសរកគូស្រករនេះ គ្មានអ្នកណាក្រៅពីមាតាបិតាឡើយ ព្រោះប្រពៃណីខ្មែរបានទៅ បង្ខំអោយក្លាយជាទម្លាប់ទៅហើយ ។ ឪពុកម្តាយត្រូវតែរើសគូស្វាមីភរិយាទុកដាក់ឱ្យកូនចៅ ។ ឯកូនចៅប្រុសស្រីក៏គ្មានសិទ្ធិអ្វីនិងដណ្តើមយកអំណាចជ្រើសរើសស្នេហា

www.budinst.gov.kh www.elibraryofcambodia.org

ដែរ ។ កូនប្រុសស្រីណាដែលហ៊ានរំលោភលើច្បាប់ប្រពៃណីត្រូវគេចាត់ទុកជាកូនអកត្តញ្ញូ មិនគោរពកោតខ្លាចឪពុកម្តាយ ហើយទុកជាកូនមិនល្អដោយ "គន្លងធម៌" ។ ក្នុងក្របខ័ណ្ឌនៃគំនិតចាស់ទុំនេះ សុភាសិតខ្មែរមួយបានបញ្ជាក់យ៉ាងច្បាស់ថា "ទំមិនធំជាងនាឡិ" ។ ដូចនេះ កូនប្រុសកូនស្រីត្រូវតែនៅក្រោមបង្គាប់ ក្រោមឱវាទឪពុកម្តាយជានិច្ច។ ការស្ថិតនៅក្រោមឱវាទនេះ មិនមែនកំណត់ត្រឹមតែក្នុងវ័យកម្លោះក្រមុំប៉ុណ្ណោះទេ តែដល់មានប្តីប្រពន្ធមានកូនបែកមែកធាងជាគ្រួសារទៅហើយនោះក៏ដោយ ក៏ត្រូវតែស្ថិតនៅក្រោមឱវាទលោកអ្នកដ៏មានគុណទាំងនេះទៀត ។ ការស្ថិតនៅក្រោមឱវាទឪពុកម្តាយជានិច្ចនេះ ជាលក្ខណៈដឹងគុណមួយរបស់កូន ។ ក្នុងសង្គមខ្មែរ ឪពុកម្តាយមានលទ្ធភាពចម្បងក្នុងការរើសគូស្រករទុកដាក់រៀបចំកូនចៅ ។

តែក្រៅអំពីនេះ នៅមានបងប្អូនមាមីងញាតិសន្តានជិតឆ្ងាយទៅទៀត ។ ឪពុកម្តាយដែលរើសប្រពន្ធ ឬ ប្តីអោយកូន

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវសង្កេតមើលថា តើបងប្អូនញាតិសន្តានជិតឆ្ងាយពេញចិត្តដែរឬទេ ? . . . នេះហើយប្រពៃណីខ្មែរ ! . . .

ដូច្នេះស្នេហាខ្មែរ ជាស្នេហាមួយដែលពឹងផ្អែកទាំងស្រុងទៅលើប្រពៃណី ។

ប្រពៃណីជាអ្នករៀបចំស្នេហាឱ្យសង្គម ។ ដូចនេះបើយើងយោលទៅតាមទ្រឹស្តីប្រពៃណី យើងឃើញថាសង្គមខ្មែរយើងគ្មានអ្វីដែលហៅថាស្នេហាឡើយ ។ បើមានស្នេហាវិញស្នេហានេះ ច្រើនតែលេចមានរូបរាងឡើងក្រោយពេលរៀបការប៉ុណ្ណោះ តែស្នេហារបៀបនេះ គេមិនហៅថាស្នេហាទេ ! . . . ប៉ុន្តែទោះជាយ៉ាងដូចម្តេចក៏ដោយ គោលការណ៍ប្រពៃណីនេះក៏មិនអាចចងឃុំឃាំងចិត្តគំនិតឧត្តមគតិ អ្នកដែលស្រឡាញ់សេរីភាពបានឡើយ ។ ពួកអ្នកសេរីភាពនិយមតែងតែប្រឆាំងជានិច្ចនឹងទំនៀមទំលាប់ទាំងឡាយណាដែលហួសសម័យ ដែលចាត់ទុកមនុស្សជាសត្វគ្មានវិចារណញ្ញាណគ្មានសេរីភាព ។ អ្នកសេរីភាពនិយម មិនត្រូវការអោយជនណាម្នាក់មកគ្រោងការណ៍

www.budinst.gov.kh www.elibraryofcambodia.org

រៀបចំតុបតែងអនាគតឡើយ ។ គេត្រូវការមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការចាត់ចែងរៀបចំជីវិតអនាគតគេដោយផ្ទាល់ដៃនឹងដោយគំនិតគេផ្ទាល់ ។

ដូច្នេះហើយ បានជាយើងកត់សំគាល់ឃើញថាក្នុងសង្គមមនុស្សសព្វថ្ងៃនេះ សេចក្ដីស្នេហាមានទម្រង់ទ្រង់ទ្រាយខុសទៅលើឧត្តមគតិ នឹងផលប្រយោជន៍ផ្សេង ៗ ពីគ្នា ។

## ២. ស្នេហាកូនសេដ្ឋី

ទម្រង់ទីមួយគឺស្នេហាកូនសេដ្ឋី កូនអ្នកមានទ្រព្យសម្បត្តិសំបូណ៌ហូរហៀរ ។ ចាស់ៗខ្លះកាលណាមានកូនដែលមានសញ្ញាប័ត្របន្តិចបន្តួច ក៏ចាប់ផ្ដើមរឹតត្បិតធ្វើដូចម្ដេចរកដណ្ដឹងភ្ជាប់អ្នកមានទ្រព្យសម្បត្តិច្រើន ឱ្យអោយកូនប្រុសរបស់ខ្លួន ។ គាត់យល់ថា យកធ្វើអ្វីកូនអ្នកក្រ?. . . យកកូនអ្នកមានប្រសើរជាង!. . . បើយកកូនអ្នកមាន នោះយើងនឹងមានស្រាប់ មិនបាច់ទៅខំរកឱ្យ ហត់ទៀតឡើយ ។ ចុះបើយកកូន

www.budinst.gov.kh www.elibraryofcambodia.org

អ្នកក្រវិញ នោះវានៅតែក្ររហាម. . . ព្រោះបន្តិចខ្វះនេះ បន្តិចខ្វះនោះ ! មិនដឹងជាពេលណាទើបមាន ទើបបានឡើយ ។ លោកសេដ្ឋីឪពុកនាងកេសរមាលា ស្អប់ខ្ពើមចៅប្រទបចេកណាស់ ព្រោះចៅស្រទបចេកនេះក្រីក្ររហាមដូចប្រេត ។ ឯនាងកេសរមាលាសោត ក៏ត្រូវឪពុកហាមជាដាច់ខាតមិនឱ្យស្រឡាញ់ចៅស្រទបចេកដែរ ។ យាយទួនវិញ ខំប្រឹងណាស់អរណាស់កាលបើណែសិត កូនសេដ្ឋីចូលមកដណ្តឹងនាងវិធារី គាត់ភ្លេចរស់ខសន្យា ពីរឿងភ្ជាប់ពាក្យទាំងប៉ុន្មានជាមួយនឹងគ្រួសារប៉ុនធឿន ។

នេះជាគំនិតចាស់ទុំដែលចង់ឱ្យកូនមានបាន មានមុខមានមាត់ ។ សព្វថ្ងៃនេះក្នុងសម័យវិទ្យាសាស្ត្រគេសង្កេតឃើញថា យុវជនភាគខ្លះ ដែលចង់ហាក់លោតតោងឱ្យទាន់សម័យទំនើប ក៏បែកគំនិតគិតប្រាថ្នាស្នេហា តែម្តងឱ្យសម្រេចបានគោលបំណងពីរដែរ ។ មួយគឺបានប្រពន្ធបានខ្លួនហើយមួយទៀតគឺ បានប្រាក់បានលុយទៀត. . . ។ ឯចំពោះបញ្ហាសុភមង្គល

www.budinst.gov.kh www.elibraryofcambodia.org

វិញ ៖គេរវល់ណាស់ !... ហើយគេក៏គ្មានពេលនឹងគិតអំពីវា ដែរ !... គេគិតតែអំពីលុយ !!!... គេជឿជាក់ថាលុយ នេះ ហើយ សម្បត្តិទ្រព្យនេះហើយ ដែលអាចផ្តល់មកនូវសុភមង្គល ។

៣-ស្នេហាកូននាម៉ឺន

ជនមួយជំពូកទៀត គេគិតឆ្ងាយហួសពីនេះនៅទៀត គឺ ត្រូវការតែកូននាម៉ឺនណាដែលមានបុណ្យសក្តិធំៗ ។ កូនចៅនាម៉ឺន តូចតាចគេមិនយកភ្នែកមើលទេ !... គេសំដៅរកកូន នាម៉ឺនធំៗព្រោះ គេត្រូវការចង់បានក្រុមបក្សពួក (parti) ។ កាលណាគេបានធ្វើជាកូនប្រសាអ្នកធំណាម្នាក់ហើយ នោះគេ អាចសង្ឃឹមថាថ្ងៃក្រោយគេនឹងបានឡើងធ្វើធំ និង បានកាន់ កន្លែងខ្លាញ់ ។ កាលណាកាន់កន្លែងខ្លាញ់ហើយ គេយល់ ថាប្រាក់មុខតែហូរចូលដោយឯកឯង ។ បើយ៉ាងនេះ គេមុខ ជាអាប់ មានទ្រព្យសម្បត្តិបរិបូណ៌ឥតឧបមាជាមិនខាន ។ បើជាមានរឿងរ៉ាវសៅហ្មងអ្វីទៅវិញនោះ ក្រុមគេនិងបក្សពួកឪ

www.budinst.gov.kh www.elibraryofcambodia.org

ក្មេកគេ មុខជាជួយរស់ពីដៃជើងជាមិនខាន ។ តើអ្នកណាអាចធ្វើអ្វីគេកើត ? . . . អ្នកហោពួមកថា កូនប្រសារអ្នកនេះ កូនប្រសារអ្នកនោះ មុខតែស្រៀវឆ្អឹងខ្នងមុនជាមិនខាន ។ ជនជំពូកនេះគេចាត់ទុកស្នេហាជាឧបករណ៍មួយ សម្រាប់ដឹកនាំផ្លូវជូនដំណើរគេទៅរកប្រាក់កាស់ដែលគេជឿជាក់ថា ជាប្រភពនៃសុភមង្គលដូចជនជំពូកមុនដែរ ។

## ៤. ស្នេហាចិត្តនិងចិត្ត

ឯស្នេហាចិត្តនិងចិត្តនេះវិញ ជាស្នេហាមួយដែលស្ថិតនៅលើឧត្តមគតិទីរងទេរ ។ ស្នេហាចិត្តនិងចិត្តពុំត្រូវការពឹងផ្អែកលើប្រាក់កាស់ លើបក្សពួកលើសម្ភារៈនិយមទេ ។ ស្នេហាចិត្តនិងចិត្តពឹងផ្អែកទៅលើកម្លាំងចិត្ត លើវិចារណញ្ញាណ ព្រោះគេយល់ថាសុភមង្គលពិតប្រាកដមែន ៗ មិនមែនស្ថិតនៅលើ សម្ភារៈទេ ! តែសុភមង្គលនេះស្ថិតនៅលើចិត្ត ។ បើកាលណាចិត្តយើងនេះសព្វព្រះហឫទ័យពេញគ្រប់គ្រាន់ហើយ ពេលនោះ យើងលែងត្រូវការអ្វីទៀតហើយ ។ បើយើងមាន

www.budinst.gov.kh www.elibraryofcambodia.org

តែលុយ តែបើចិត្តឥតសប្បាយរីករាយ តើយើងអាចសប្បាយរួចដែរឬទេ ? . . . តើដល់ស្លាប់ទៅយើងអាចស្ពាយបេកសំបុកសម្បត្តិលុយកាក់ប្រាក់កាសទាំងនេះទៅជាមួយ បានដែរឬ ?...

នេះហើយជាផ្គត់គំនិតរបស់ជនជំពូកដែលមានស្នេហាចិត្ត និងចិត្ត ។ បញ្ហាដែលចោទធំបំផុតចំពោះពួកគេ គឺធ្វើដូចម្ដេចឱ្យតែចិត្តគេអាចបំពេញបំណងបានដោយគ្រប់គ្រាន់ ។ គេយល់ម្យ៉ាងទៀតថាបើខ្វះចិត្ត យកចិត្តមកប៉ះទើបបាន តែបើយកប្រាក់មកប៉ះវិញមិនបានជាដាច់ខាត ។ គេមិនសុខចិត្តឱ្យសម្ភារៈមកគ្របដណ្ដប់ជិះជាន់លើឧត្ដមគតិ លើផ្លូវចិត្តបានឡើយ ។ សូវអោយពិបាកកាយកុំអោយតែពិបាកចិត្ត ។

ដូច្នេះបើយើងផ្អែកទៅលើភាពឧត្ដមគតិស្នេហាផ្អែកខាងក្រោយនេះយើងអាចយល់បានយ៉ាងច្បាស់ថា ការស្នេហាចិត្ត និងចិត្តនេះត្រូវការសេរីភាពក្នុងការរើសគូស្រករ ហើយផ្អែកទៅលើចិត្តត្រិះរិះគិតយល់ឃើញទាំងស្រុង ដោយប្រឆាំងជាដាច់ខាតនឹងស្នេហារបៀបសម្ភារៈនិយម ។ ស្នេហាចិត្តនិងចិត្តនេះ

www.budinst.gov.kh www.elibraryofcambodia.org

ជាលក្ខណៈមួយប្រឆាំងនឹងប្រពៃណី ។ ជាពិសេសទៅទៀត នៅក្នុងសង្គមខ្មែរយើង ស្នេហាចិត្តនិងចិត្តនេះផ្ទុយស្រឡះនិងផ្នត់គំនិតខ្មែរទាំងស្រុង ហើយវាជាហេតុភេទមួយដែលគេមិនត្រូវការចង់ដឹងឮសោះឡើយ ។ គេត្រូវការធ្វើដូចម្ដេចអោយបាត់នូវអាកេរ្តិ៍ដ៏ស្អុយគគ្រុកបែបនេះតែប៉ុណ្ណោះ ។

បើបញ្ហាបានចោទឡើងយ៉ាងធ្ងន់ដូចនេះ តើយុវជនយើងដែលជាអ្នកបម្រុងសម្រួលនិងកសាងអនាគត ឧត្តមគតិមនុស្សជាតិត្រូវជ្រើសរើសយកស្នេហារបៀបណា ? . . .

រស់ ចន្ត្រាបុត្រ

www.budinst.gov.kh www.elibraryofcambodia.org